# ជីវប្រវត្តិរបស់ព្រះសាស្ដា

# មូហាំម៉ាដ់ صلى الله عليه وآله وسلم



សៃយីដ្ទ ម៉ាស្ទ់ឌី អាយ៉ាទុលឡ៏ហ៊ី

ស្មាគីប បេនបេឌីរ៉ា

# បញ្ជីមាតិកា


ជីវប្រវត្តិរបស់ព្រះសាស្តាមូហាំម៉ាត់ﷺ ..... 4

១. នៅឯម៉ាក់កាស់ ..... 4

គូរ៉យស៍ និង ហាស៊ីម ..... 4

អាប់ឌុលមុត្តាលិប និង អាប់ឌុលឡោះហ៍ ..... 4

កុមារភាព និង យុវភាពរបស់ព្រះសាស្តាﷺ ..... 5

រស្មីនៃប្រាជ្ញាញាណរបស់មូហាំម៉ាត់ﷺ ..... 7

ការទទួលវ៉ាហ៊ី ..... 7

ការចាប់ផ្តើមកៀបសង្កត់ ..... 8

សាសនាអ៊ីស្លាមប្រឈមនឹងសង្គ្រាមសេដ្ឋកិច្ច ..... 9

ហ៊ីជរ៉ោះត៍(ការភៀសខ្លួន) ..... 9

២. ក្រោយហ៊ីជរ៉ោះត៍ ..... 12

រដ្ឋអ៊ីស្លាមដំបូងបង្អស់ ..... 12

ការផ្លាស់ប្តូរទិសនមស្ការ(ស៊ិ៍ឡាត់) ..... 12

ការការពារសាសនាអ៊ីស្លាម ..... 13

១-សមរភូមិបាដ់រ៍ ..... 13

២-សមរភូមិអ៊ូហ៊ុដ ..... 14

៣-សមរភូមិខាន់ដាក់(الخندق) ..... 16

៤-ការធ្វើទណ្ឌកម្មពួកបនក្បត់ ..... 19

៥-យុទ្ធសន្តិភាពហ៊ុដៃបីយ៉ាស់(صلح الحديبية) ..... 19

៦-សមរភូមិខុយបារ ..... 22

ហ្វាដាក់(فدك) ..... 24

៧-សមរភូមិមុតាស់(مؤتة) ..... 25

៨-ភាគីគូរ៉យស៍ក្បត់កិច្ចសន្យាហ៊ុដៃបីយ៉ាស់ ..... 25

៣. ក្រោយជ័យជំនះ ..... 28

ការវាយដណ្តើមយកនគរម៉ាក់កាស់ ..... 28

ការលើកលែងទោសទូទៅ ..... 29

សមរភូមិហ៊ុណៃន៍(حنين) ..... 30

សមរភូមិតាប៊ុក(تبوك) ..... 31

ម៉ាស់យ៊ិដរបស់ពួកលាក់ពុតត្បុត ..... 31

ឆ្ពោះទៅកាន់តាប៊ុក ..... 31

ផែនការសម្ងាត់របស់ពួកលាក់ពុតត្បុត ..... 33

ការបដិសេធពួកពហុទេពនិយម ..... 33

ការដាក់បណ្តាសា(مباهلة) 34
ធម្មយាត្រាលាគ្នា(حجة الوداع) 35
នៅឯបឹងឃុម 36
ព្រះទិវង្គត 38
អត្តសញ្ញាណប័ណ្ណ 38
សម្រង់ព្រះវចនៈត្រចះត្រចង់ 39

# ជីវប្រវត្តិរបស់ព្រះសាស្តាមូហាំម៉ាដ់ﷺ

## ១. នៅឯម៉ាក់កាស់

## គូរ៉យស៍ និង ហាស៊ីម

គូរ៉យស៍ជាឈ្មោះរបស់កុលសម្ព័ន្ធអារ៉ាប់មួយដែលរស់នៅឯតំបន់ហ៊ីយ៉ាស់ ពោលគឺ នៅខាងលិចនៃឧបទ្វីបអារ៉ាប់។ កុលសម្ព័ន្ធនេះមានឈ្មោះបោះសម្លេងនិងមានកិត្យានុភាពលើសអស់កុលសម្ព័ន្ធអារ៉ាប់ឯទៀត។

កុលសម្ព័ន្ធគូរ៉យស៍មានកិត្តិនាមដោយសារជីតាទី ៤ របស់ព្រះមហាសាស្តាមូហាំម៉ាដ់ﷺយើង ដែលមាននាមថាគូស្វៃ ប៊ិន គីឡាប់ដែលមានកិត្តិយសត្រួតត្រាការទាំងឡាយនៃព្រះមហាគ្រឹះ គឺកាក់បាស់ដែលនគរម៉ាក់កាស់ត្រូវសាងសង់ឡើងនៅជុំវិញនោះ។

ត្រកូលធំៗបួនរួមជាកុលសម្ព័ន្ធគូរ៉យស៍។ ត្រកូលរុងរឿងជាងគេគឺត្រកូលរបស់បណ្តាកូនចៅរបស់ហាស៊ីមដែលជាអំបូររបស់ព្រះសាស្តាចុងក្រោយបង្អស់។
ហាស៊ីមល្បីល្បាញដោយសារលោកមានចិត្តទូលាយ មានសប្បុរសធម៌ហើយអ្នកស្រុកម៉ាក់កាស់គោរពលោក។ ការពិតកេរ្តិ៍ឈ្មោះលោកលេចឮហួសព្រំដែននគរនេះទៅទៀត ព្រោះលោកមានមុខងារជាអ្នករៀបចំចំណីអាហារឲ្យបូជនីយេសក៏ដែលមកកាន់ព្រះមហាគ្រឹះពិសិដ្ឋ រៀងរាល់រដូវបំពេញពិធីបូជនីយេសចរណ៍(ពិធីហាច្ជ)។

ហាស៊ីមទទួលបានសម្មតិនាមលោកចាប់តាំងពីឆ្នាំរាំងស្ងួតមួយមកម្ល៉េះ ដែលការអត់ឃ្លានបានពើបប្រទះលើតំបន់។ កុលសម្ព័ន្ធគូរ៉យស៍ត្រូវការអត់ឃ្លាននេះយាយីយ៉ាងដំណំ។
កាលនោះ លោកជាជនដំបូងបង្អស់ដែលបានដាំបបរនំបុ័ងយកទៅចែកឲ្យបរិភោគ មនុស្សម្នាក៏បានចំអែតអាត្មាបំបាត់ការស្រេកឃ្លាន។
លើសពីនោះ ហាស៊ីមជាអ្នកដំបូងបង្អស់ដែលបានចាត់ចែងការជួញដូរធំៗក្នុងរដូវរងានិងរដូវក្តៅ។ ដូច្នេះឯងបានជាលោកបានទទួលសម្មតិនាមថាសៃយីដ្ធ(លោកម្ចាស់ ជាការហៅដែលមានរហូតមកដល់សព្វថ្ងៃប្រើសម្រាប់តែបណ្តាកូនចៅលោកប៉ុណ្ណោះ)។

## អាប់ឌុលមុត្តត៌លិប និង អាប់ឌុលឡោះហ៍

បន្ទាប់ពីហាស៊ីម អាប់ឌុលមុត្តត៌លិបជាអ្នកដឹកនាំផ្នែកសាសនានិងផ្នែកសីលធម៌របស់កុលសម្ព័ន្ធគូរ៉យស៍

ហើយនៅក្នុងសម័យលោកនេះឯងដែលស្តេចនគរហាប់ស្ហាស់(الحبشة ប្រទេសអេត្យូពីសព្វថ្ងៃ)ដែលមាននាមថា អាប់រ៉ហ្វាស់(أبرهة)មានបំណងបំផ្លាញកាក់បាស់ តែអាស្រ័យព្រះមហិទ្ធិឫទ្ធិអល់ឡោះហ៍ ព្រះដ៏មហាខ្ពង់ខ្ពស់ បុគ្គលអាក្រក់រូបនេះនិងកងទ័ពរបស់ខ្លួនវិនាសសូន្យបង់ក្បែរព្រះមហាគ្រឹះពិសិដ្ឋ។

ព្រឹត្តិការណ៍អស្ចារ្យដ៏សម្បើមនេះធ្វើឲ្យអ៊ាប់ឌុលមុត្តត៍លិបកាន់តែមានកិត្យានុភាពទ្វេឡើង។ គោលជំហរលោកក្នុងចំណោមកុលសម្ព័ន្ធអារ៉ាប់ទាំងអស់នោះកាន់រឹងមាំឡើង។

អ៊ាប់ឌុលមុត្តត៍លិបមានកូនច្រើន តែអ៊ាប់ឌុលឡោះហ៍ជាកូនល្អជាងគេ ក្នុងចំណោមកូនៗទាំងអស់ ហើយជាកូនដែលគួរឲ្យស្រឡាញ់ជាងគេ។

អ៊ាប់ឌុលឡោះហ៍មានអាយុម្ភៃឆ្នាំកាលលោករៀបអាពាហ៍ពិពាហ៍ជាមួយអាមីណាស់ បុត្រីរបស់វ៉ាហ្វាប់ (آمنة بنت وهب)។ ព្រះសាស្តា ព្រះបរមគ្រូﷺយើងបានចាប់បដិសន្ធិពីអាពាហ៍ពិពាហ៍ដែលប្រកបដោយពរជ័យសិរីសួស្តីនេះ៕

## កុមារភាព និង យុវភាពរបស់ព្រះសាស្តាﷺ

ព្រះសាស្តាឪចបានចាប់បដិសន្ធិពីរខែក្រោយពីឆ្នាំដំរី គឺឆ្នាំដែលទ័ពរបស់អាប់រ៉ហ្វាស់ត្រូវវិនាស។ ព្រះបិតារបស់ព្រះមហាសាស្តាﷺយើងបានចូលទិវង្គតកាលព្រះអគ្គមហេសីព្រះអង្គមានគភ៌នៅឡើយ។

លុះអាមីណាស់ប្រសូតព្រះរាជទារកដ៏មហារុងរឿងនៃទូទាំងចក្រវាល ព្រះអយ្យកោដែលមាននាមថា អ៊ាបឌុលមុត្តត៍លិបបានទទួលព្រះរាជទារកមកចិញ្ចឹម។ ដូច្នេះមូហ៊ាំម៉ាដ់ﷺបានស្ថិតនៅក្រោមអាណាព្យាបាលរបស់ជីតាដ៏ល្បីល្បាញអស់រយៈពេលដ៏ក្រែលនៃកុមារវ័យព្រះអង្គﷺ។ ជីតាព្រះអង្គﷺជាព្រះសំណាងកំព្រាភាពរបស់ព្រះបរមគ្រូ ព្រះសាស្តាﷺយើង។

តាំងពីវ័យកុមារមកម្ល៉េះ មូហ៊ាំម៉ាដ់ﷺមានកេរ្តិ៍ឈ្មោះលើសធម្មតា។ អ្នកស្រុកម៉ាក់កាស់ហៅព្រះអង្គﷺតាមតែឈ្មោះក្រៅព្រះអង្គﷺទេគឺ៖ បុគ្គលស្មោះត្រង់ បុគ្គលទៀងត្រង់ ។ល។ ហើយពួកគេយកទ្រព្យនិងថវិការបស់ខ្លួនមកផ្ញើព្រះអង្គﷺ។

មូហ៊ាំម៉ាដ់ﷺស្រឡាញ់ជនក្រីក្រនិងជនខ្សត់ខ្សោយ ព្រះអង្គﷺតែងតែចែករំលែកអាហារជាមួយពួកគេ។ ព្រះអង្គﷺស្តាប់ការត្អូញត្អែររបស់ពួកគេជានិច្ច ហើយខ្នះខ្នែងដោះស្រាយបញ្ហាពួកគេឥតសំចៃកម្លាំងឡើយ។

គ្រាមួយ យុវជនម៉ាក់កាស់បានព្រមព្រៀងគ្នាបង្កើតសម្ព័ន្ធភាពមួយដែលហៅថា កតិកាសញ្ញានៃគុណាករ ដើម្បីការពារជនអន់ខ្សោយនិងជនរងការសង្កត់សង្កិន និងដើម្បីការពារសិទ្ធិរបស់ពួកគេប្រឈមនឹងជនប្រព្រឹត្តដោយអយុត្តិធម៌ឬជនសង្កត់សង្កិន។ មូហ៊ាំម៉ាដ់ﷺបានចូលរួមជាមួយពួកគេភ្លាម ហើយបានជួយនិងបានគាំទ្រពួកគេព្រោះគោលការណ៍កតិកាសញ្ញានេះស្របនឹងសីលធម៌ព្រះអង្គﷺពិតៗ។

ក្រោមការស្នើសូមរបស់ អាប៊ូត៍លិប ឪពុកមារបស់ព្រះអង្គﷺ មូហ៊ាំម៉ាដ់ﷺបានចូលរួមក្នុងក្បួនទូរចរជំនួញរបស់ខ៉ទីយ៉ាស់ ដែលជាសុភាពនារីគួរ៉យស៍ថ្លៃថ្នូរមួយរូប។ ខ៉ទីយ៉ាស់បានប្រគល់បញ្ជាការនិងការត្រួតត្រារបស់ខ្លួនឲ្យទៅមូហ៊ាំម៉ាដ់ﷺ។

លុះខ៍ឌីយ៉ាស់ុបានជ្រាបច្បាស់អំពីគុណសម្បត្តិសីលធម៌របស់មូហាំម៉ាដ់ﷺ នាងបានស្នើសូមរៀបអាពាហ៍ពិពាហ៍ជាមួយព្រះអង្គឌ៏ច ព្រះអង្គﷺក៏បានយល់ព្រម។

ខ៍ឌីយ៉ាស់ុជានារីដែលប្រកបដោយសីលធម៌ប្រពៃនិងមានទ្រព្យធន។ ការគាំទ្រនិងភក្ដីភាពទាំងស្រុងរបស់ព្រះនាងចំពោះស្វាមីព្រះនាងសឲ្យឃើញថាព្រះនាងជានារីគំរូមួយរូបសម្រាប់មនុស្សជាតិទាំងមូល។



អាស្រ័យលើគុណសម្បត្តិទាំងនេះ ព្រះនាងស័ក្តិជាមាតាតែមួយគត់មែនរបស់បច្ឆាបុត្រធីតាបរិសុទ្ធរបស់ព្រះមហាសាស្ដាﷺ។ ពិតមែន ព្រះនាងបានប្រសូតហ្វាទីម៉ាស់ុعليها السلام នារីរុងរឿងថ្លៃថ្លា ដែលជាមាតារបស់ អាល់-

ហាសាន់(صلوات الله عليه والسلام) អាល់-ហ៊ូសៃន៍(صلوات الله عليه والسلام) និងសៃណាប់(رضي الله عنها) ប្អូនស្រីរបស់អ្នកទាំងពីរ។ អ៊ីម៉ាំអាស្ហ៊ូលុលបៃត៍ប្រាំបួនអង្គនឹងប្រសូតមកពីអាល់-ហ៊ូសៃន៍(صلوات الله عليه والسلام) ចៅរបស់ព្រះនាង ពីមួយទៅមួយ ដើម្បីប្រោសស្រោចស្រង់ភពផែនដែនចក្រវាល។

## រស្មីនៃប្រាជ្ញាញាណរបស់មូហាំម៉ាដ់ﷺ

ដប់ឆ្នាំក្រោយពីខ៍ឌីយ៉ាស្ហ៊ុនិងមូហាំម៉ាដ់ﷺបានរៀបអាពាហ៍ពិពាហ៍ ទឹកជំនន់បានលិចនគរម៉ាក់កាស្ហ៊ុបណ្ដាលឲ្យព្រះមហាគ្រឹះខូចខាតយ៉ាងដំណំ។

ពួកគូរ៉យ៉ស្ហ៍បានសម្រេចចិត្តសាងសង់កាក់បាស្ហ៊ុឡើងវិញ កិត្តិយសនេះបានលើកុលសម្ព័ន្ធទាំងអស់។ លុះបានសាងសង់រួចហើយ ដល់ពេលដាក់ថ្មខ្មៅទៅកន្លែងវាវិញ។ ពួកគូរ៉យ៉ស្ហ៍គ្រប់ត្រកូលដណ្ដើមគ្នាយកកិត្តិយសដឹកជញ្ជូនថ្មខ្មៅនេះ។

មិនយូរប៉ុន្មាន ការឈ្លោះប្រកែកគ្នានេះបាននាំអាទ៏ឲ្យកើតមានការប្រយុទ្ធគ្នាដោយអាវុធ។

ក្នុងឱកាសដុនដាបនេះ មូហាំម៉ាដ់ﷺបានធ្វើអន្តរាគមន៍ដើម្បីរម្ងាប់អារម្មណ៍និងនាំមកវិញនូវសន្តិសុខនិងការស្រុះស្រួលគ្នា ដោយស្នើសូមឲ្យកុលសម្ព័ន្ធទាំងអស់ដែលឈ្លោះប្រកែកគ្នានោះមកចូលរួមទាំងអស់គ្នាក្នុងកិត្តិយសដ៏ធំនេះ។ ព្រះអង្គﷺបានដោះអាវធំ បានដាក់អាវនោះលើដី បានយកថ្មខ្មៅផ្ទាល់ព្រះហត្ថព្រះអង្គﷺមកដាក់លើអាវធំនោះ ហើយបានអញ្ជើញកុលសម្ព័ន្ធទាំងអស់មកដឹកជញ្ជូនថ្មខ្មៅនោះដោយកាន់ក្រណាត់អាវនោះម្នាក់មួយអន្លើៗ៕

## ការទទួលវ៉ាហ៊ី

ចាប់តាំងពីមូហាំម៉ាដ់ﷺមានព្រះជន្មសែសិបវស្សាមកម្ល៉េះហើយ ព្រះអង្គﷺតែងតែចាកចេញពីនគរម៉ាក់កាស្ហ៊ុទៅស្នាក់នៅឯគុហាភ្នំហ៊ីរ៉អ៍(حراء)។ នាទីនេះ ព្រះអង្គﷺគិតតែធ្វើសក្ការៈបូជាអល់ឡោះហ្ស៍(عز وجل) ព្រះមួយគត់ដែលព្រះអង្គﷺបានស្គាល់ឬបានធ្វើសក្ការៈ។

ក្នុងខែរ៉ម៉ាដ្ហនថៃឆ្នាំនោះ ទេវតាយ៉ីបរ៉អ៊ីលបានចុះមកជួបមូហាំម៉ាដ់ﷺក្នុងគុហាភ្នំហ៊ីរ៉អ៍ ហើយបាននាំដំណឹងធំមកប្រាប់ព្រះអង្គﷺគឺ៖ សាស្ដានិងបេសកកម្មរបស់អ្នកនាំព្រះរាជសាររបស់អល់ឡោះហ្ស៍(عز وجل)។

មូហាំម៉ាដ់ﷺកំពុងតែចម្រើនភាវនា អារម្មណ៍ព្រះអង្គﷺផ្ដោតទៅរកអល់ឡោះហ្ស៍(عز وجل)ទាំងស្រុង ព្រះដ៏មានព្រះមហិទ្ធិឫទ្ធិនៅពេលដែលយ៉ីបរ៉អ៊ីលបានហៅព្រះអង្គﷺដោយព្រះបន្ទូលអល់ឡោះហ្ស៍(عز وجل)ថា៖

*ចូរអ្នកស្រូតទៅ ក្នុងព្រះនាមព្រះម្ចាស់អ្នក...* (ស៊ូ.៩៦, អា.១)។

នេះគឺអាយ៉ាស្ហ៊ុដំបូងបង្អស់របស់គួរអាន។

មូហាំម៉ាដ់ﷺចុះមកពីលើភ្នំវិញ ដែលសព្វថ្ងៃគេហៅថាភ្នំអាន់-នូរ(النور)ដែលមានចម្ងាយប្រមាណ ៦ គីឡូម៉ែត្រពីម៉ាក់កាស់ សំដៅទៅរកមនុស្សជាតិទាំងអស់ដើម្បីផ្សាយព្រះរាជសារ តាមព្រះរាជបញ្ជារបស់ព្រះម្ចាស់ﷻនៃពិភពទាំងពួង។

កាលពីដើមឡើយ ការផ្សព្វផ្សាយជំនឿបរិសុទ្ធស្ថិតនៅក្នុងអាថិកំបាំងនៅឡើយ។ ជនដំបូងបង្អស់ដែលព្រមជឿគឺៈ ខ៍ឌីយ៉ាស់ ក្នុងចំណោមពួកស្រ្តី និងអាលី បងប្អូនជីដូនមួយរបស់ព្រះសាស្តាដែលព្រះអង្គបានយកមកចិញ្ចឹម ក្នុងចំណោមពួកបុរស។

## ការចាប់ផ្តើមកៀបសង្កត់

បីឆ្នាំបានកន្លងផុតទៅ សាសនាអ៊ីស្លាមបានសាយភាយយ៉ាងយឺតៗតែប្រាកដប្រជានៅក្នុងចំណោមជនក្រីក្រអភ័ព្វនៃនគរម៉ាក់កាស់។ បន្ទាប់ពីនោះ ព្រះរាជបញ្ជារបស់អល់ឡោះហ្ជ័ﷻ ព្រះដ៏មហាខ្ពង់ខ្ពស់ បានមកដល់ព្រះសាស្តាﷺព្រះអង្គﷻ ថាឲ្យប្រកាសអត្ថន័យរបស់ព្រះរាជសារព្រះអង្គﷻ។

នៅក្នុងបរិយាកាសប្រទូសប្រឆាំងនិងក្នុងបរិយាកាសដែលមានតែជំនឿលើរូបបដិមានោះ ព្រះសាស្តាមូហាំម៉ាដ់ﷺបានប្រកាសថាៈ

*ខ្ញុំសូមប្តេជ្ញាថាពុំមានព្រះផ្សេងពីអល់ឡោះហ្ជ័ﷻទេ ហើយខ្ញុំជាព្រះសាស្តារបស់អល់ឡោះហ្ជ័ﷻ។*

ក្រោយពីការប្រកាសនេះ ពួកគូរ៉យស៍ពហុទេពនិយមបានអុជភ្លើងទោសៈបានចាប់ផ្តើមទូងស្គរសង្រ្គាមប្រឆាំងជំនឿអ៊ីស្លាមព្រោះពួកគេយល់ឃើញថាវានឹងផ្តល់គ្រោះថ្នាក់ដល់ផលប្រយោជន៍ និងដល់ឯកសិទ្ធិមិនត្រឹមត្រូវរបស់ពួកគេ។

មុនដំបូងពួកគេបានសាកល្បងសូកប៉ាន់នាំឲ្យព្រះសាស្តាﷺខូចនិងទិញព្រះអង្គﷺឲ្យបិទមាត់ជិត ដោយដាក់ឲ្យព្រះអង្គﷺនូវទ្រព្យសម្បត្តិយ៉ាងសម្បើមនិងអំណាចធំមួយ ឲ្យតែព្រះអង្គﷺព្រមលះបង់ចោលជំនឿអ៊ីស្លាម។ តែការខំប្រឹងប្រែងរបស់ពួកគេនោះមិនបានប្រយោជន៍ទេ។

លុះពួកគូរ៉យ៉ស៍ពហុទេពនិយមបានឃើញសេចក្តីសម្រេចចិត្តយ៉ាងមោះមុតរបស់ព្រះសាស្តាﷺ ពួកគេបានជ្រើសយកវិធីតឹងរ៉ឹង ហើយបានចាប់ផ្តើមសង្កត់សង្កិនជនទាំងឡាយណាដែលចុះចូលសាសនាថ្មីនេះ។ ជនទាំងនេះមិនមានបុណ្យស័ក្តិវណ្ណៈការពារទេ។

ដូច្នេះ ជនណាក្រីក្រអន់ខ្សោយជាងគេ ជននោះត្រូវគេធ្វើទារុណកម្មរហូតដល់ស្លាប់។ ជនឯទៀតអាចអត់ទ្រាំទារុណកម្មបាន អាចយកជីវិតរួចបាន។ រីឯមុស្លីមមួយចំនួនទៀតដែលអាចជ្រកក្រោមត្រកូលខ្លួនបាន ឬមានកុលសម្ព័ន្ធជួយកាពារបាន បានទទួលរងការចំអកនិងត្រូវគេជេរប្រទេចគ្រប់ទិសទី។

លើសពីនោះ ទ្រព្យសម្បត្តិពួកគេត្រូវគេរឹបអូសយក។ រាល់គ្រាដែលកុលសម្ព័ន្ធឬត្រកូលពួកគេអាចជួយពួកគេបាន ផ្ទះសម្បែងពួកគេក៏ត្រូវគេលួចប្លន់ដែរ។

## សាសនាអ៊ីស្លាមប្រឈមនឹងសង្គ្រាមសេដ្ឋកិច្ច

យុទ្ធការសង្កត់សង្កិននេះមិនសូវមានប្រសិទ្ធិភាព ក្នុងការរាំងរាជំនឿចំពោះអល់ឡោះហ៊្វ៍ﷺមិនសាយរាយខ្ចរខ្ចាយនោះទេ។ ផ្ទុយទៅវិញ រាល់គ្រាដែលការសង្កត់សង្កិនមានលក្ខណៈសម្បើមគួរឲ្យទាក់ទាញចក្ខុ ព្រះរាជសារកាន់តែលេចព្ធនិងកាន់តែជ្រាបទៅដល់សតិអារម្មណ៍ដែលស្រេកឃ្លានយុត្តិធម៌៕

ដំណើរទៅមុខនៃព្រះរាជសារអ៊ីស្លាមដែលមិនអាចទប់បាននោះ បានបណ្ដាលឲ្យពួកមេដឹកនាំពួកពហុទេពនិយមប្រើវិធីផ្ដាច់ទំនាក់ទំនងឲ្យនៅតែឯងនិងវិធីខ្ទប់ទៅលើបណ្ដាសាច់ញាតិរបស់មូហ៊ាំម៉ាដ់ﷺ និងបណ្ដាសាវ័កព្រះអង្គﷺ។

ដូច្នេះ មេត្រកូលនិងកុលសម្ព័ន្ធម៉ាក់កាស់ទាំងអស់បានចុះហត្ថលេខាធ្វើកតិកាសញ្ញាមួយដែលតម្រូវឲ្យដេញចេញពីនគរ គឺសាច់ញាតិរបស់ព្រះសាស្ដាﷺនិងបណ្ដាសាវ័កព្រះអង្គﷺ និងកុំឲ្យទិញទំនិញពួកគេ ព្រមទាំងហាមធ្វើជំនួញជាមួយពួកគេ។ បន្ទាប់ពីនោះមក បណ្ដាអ្នកមានសទ្ធាត្រូវគេព័ទ្ធជុំវិញនៅឯកន្លែងមួយដែលហៅថា ច្រកអាប៊ូ-ត៍លិប។ ពួកគេបានទទួលរងនូវការកាត់ផ្ដាច់ទំនាក់ទំនងជាមួយសង្គមនិងការខ្វះខាតសព្វគ្រប់យ៉ាងអមនុស្សធម៌នៅទីនោះ៕

ការឡោមព័ទ្ធសាច់ញាតិព្រះសាស្ដាﷺបានប្រព្រឹត្តទៅដោយឥតធម៌មេត្តា ពួកគេខ្វះខាតគ្រឿងទ្រទ្រង់ជីវិតចាំបាច់ ស្ទើរតែមិនអាចផ្ដល់ទឹកនិងស្បៀងបានទេ។ មានតែពេលខ្លះក្នុងពេលយប់ទេដែលបណ្ដាអ្នកស្មោះត្រង់ចំពោះព្រះសាស្ដាﷺបានផ្ដល់ជំនួយដល់ពួកគេបាន។

បទល្មើសបន្តិបន្តួចលើបម្រាមបិទគមនាគមន៍នេះមិនអាចរារាំងការអត់ឃ្លាន និងការស្រេកមិនឲ្យវាយប្រហារមកលើជនរងគ្រោះដោយសារបម្រាមបិទគមនាគមន៍នោះបានទេ។ សាច់ញាតិមួយចំនួនរបស់ព្រះសាស្ដាﷺបានបាត់បង់ជីវិត។ តែពួកមុស្លីមបានតស៊ូយ៉ាងខ្លាំងក្លានិងគួរឲ្យកត់សម្គាល់ រហូតដល់ធ្វើឲ្យបម្រាមបិទគមនាគមន៍នេះក្លាយទៅជាមូលហេតុនៃការខ្វែងគំនិតគ្នារវាងពួកពហុទេពនិយមគូរ៉យ៉ស្ហ៍។ ព្រោះតែខ្លាចថាការបិទទំនាក់ទំនងសេដ្ឋកិច្ចពួកមុស្លីមនេះនឹងទាក់ទាញសមានចិត្តពួកអារាប់ទូទៅ បានជាពួកបដិសេធសទ្ធាបានលើកបម្រាមបិទគមនាគមន៍នេះចោលវិញ ហើយបានចាប់ផ្ដើមរៀបចំផែនការណ៍កម្ចាត់ព្រះសាស្ដាﷺនិងបណ្ដាសាវ័កព្រះអង្គﷺជាស្ថាពរ។ នៅក្នុងអង្គប្រជុំសម្ងាត់មួយ នៅឯទីប្រជុំ(ដ្ធារ អាន់-ណាដ្ធ៉ាស្វ៉) ពួកគេបានសម្រេចចិត្តធ្វើគុតព្រះសាស្ដាមូហ៊ាំម៉ាដ់ﷺ។

## ហ៊ីច្រ៉ោះត៍(ការភៀសខ្លួន)

ព្រះសាស្ដាﷺបានទទួលវ៉ាហ៊្យី(ការបើកឲ្យដឹងពីអល់ឡោះហ៊្វ៍عزوجل) ប្រាប់ឲ្យដឹងអំពីផែនការណ៍របស់ពួកបដិសេធសទ្ធា។ ព្រះអង្គﷺបានស្នើឲ្យអ៊ាលីصلوات الله عليه والسلام ប្អូនជីដូនមួយព្រះអង្គﷺ មកផ្ទំនៅឯផ្ទះព្រះអង្គﷺជួសព្រះ

អង្គﷺដើម្បីនឹងអាចចាកចេញពីម៉ាក់កាស់បានក្នុងយប់ឃាតកម្មនោះ។



ប្អូនជីដូនមួយដ៏ស្មោះត្រង់របស់ព្រះអង្គﷺ ក៏បានយល់ព្រមទទួលការស្នើសូមរបស់ព្រះបរមគ្រូរបស់ខ្លួនឥតរួញរាឡើយ។ ដូច្នេះ ព្រះសាស្តាﷺអាចចាកចេញពីម៉ាក់កាស់បានទាំងយប់ដោយឥតឲ្យពួកសត្រូវដឹងខ្លួនឡើយ។

លុះពួកសត្រូវបានវាយលុកចូលក្នុងផ្ទះព្រះសាស្តាﷺដើម្បីអនុវត្តិតាមផែនការណ៍ក្បត់ ពួកគេបានភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលមិនបានប្រទះមូហ៊ាំម៉ាដ់ﷺទេនោះ បែរជាប្រទះអ៊ាលីعليه والسلام صلوات اللهនៅទល់មុខគ្នានោះវិញ ដែលត្រៀមខ្លួនប្រយុទ្ធជាស្រេច។

ពួកបដិសេធសទ្ធាភ័យស្លន់ស្លោខ្លាំង ក៏បានរត់គេចខ្លួនទៅប្រាប់ពួកមេដឹកនាំពួកពហុទេពនិយម។ ពួកគេក៏បានចាត់ចែងភ្លាមនូវយុទ្ធនាការមួយដើម្បីដេញតាមព្រះសាស្តាﷺ ៕

នៅក្រោមជម្រកអល់ឡោះហ្ទ៍عزوجل មូហ៊ាំម៉ាដ់ﷺបានគេចផុតពីពួកដេញតាមព្រះអង្គﷺនោះដែលបានត្រឡប់មកម៉ាក់កាស់វិញដែទទេ។

បន្ទាប់ពីបានធ្វើដំណើរប្រាំបួនថ្ងៃ ព្រះសាស្តាﷺអល់ឡោះហ្ទ៍عزوجلក៏បានមកដល់គោលដៅ គឺនគរយ៉ាស្រ៉ីប (ម៉ាឌីណាស់)។ ពួកអ្នកស្រុកមុស្លីមបានទទួលព្រះអង្គយ៉ាងអធិកអធមក្រៃលែង។ ពួកគេដណ្តើមគ្នាយកកិត្តិយសបម្រើព្រះអង្គﷺ។ នៅឯកន្លែងមួយនៃនគរយ៉ាស្រ៉ីបដែលហៅថា គូ៏បាអ៍(قباء) ព្រះអង្គﷺបានបញ្ជាឲ្យសាងសង់ម៉ាស់យ៊ីដ្ធអ៊ីស្លាមដំបូងបង្អស់។ ការសាងសង់បានចាប់ផ្តើមដោយសេចក្តីសោមនស្សរីករាយដែលគួរយកជាគំរូ។ ព្រះសាស្តាﷺបានចូលរួមដោយផ្ទាល់ដែរ។

ដូច្នេះ ក្រោយពីព្រះសាស្តាﷺបានមកដល់នគរយ៉ាស្រ៉ីប ស្ហ្ទឡាត់ថ្ងៃសុក្រដំបូងបង្អស់បានប្រព្រឹត្តិឡើងនៅក្នុងម៉ាស់យ៊ីដ្ធប្រកបដោយសិរីសួស្តីនេះ។

នគរយ៉ាស្រ៉ីបត្រូវដាក់ឈ្មោះឡើងវិញភ្លាមថា អាល់-ម៉ាឌីណាស់ដោយព្រះសាស្តាﷺផ្ទាល់តែម្តង។ ព្រះអង្គﷺបានស្នាក់នៅឯស្រុកនេះជាមួយពួកអ្នកស្រុកនេះដែលហៅថា អាន់ស្វារ(ពោលគឺ អ្នកជំនួយ យុទ្ធិកៈបាសាទិកៈ) ដើម្បីបង្ហាត់បង្រៀនពួកគេនូវព្រះគម្ពីរគួរអាននិងចំណេះវិជ្ជាដែលមកពីព្រះ។

ព្រះអង្គﷺរង់ចាំអ៊ាលីصلوات الله عليه والسلام ប្អូនជីដូនមួយភក្តីរបស់ព្រះអង្គﷺ មកតាមព្រះអង្គﷺ។ ព្រះសាស្តាﷺបានដាក់បេសកកម្មឲ្យអ៊ាលីصلوات الله عليه والسلامប្រគល់បញ្ញើ ដែលគេបានយកមកផ្ញើនៅឯផ្ទះព្រះអង្គﷺនោះទៅម្ចាស់បញ្ញើវិញ ហើយឲ្យអ៊ាលីصلوات الله عليه والسلامនាំបណ្តាស្រ្តីនិងក្មេងៗបានី-ហ្វាស៊ីមមកជាមួយព្រះអង្គصلوات الله عليه والسلامតាមក្រោយ។ នៅពេលរង់ចាំពួកគេមករកព្រះអង្គﷺនេះ ព្រះសាស្តាﷺបានចាប់ផ្តើមធ្វើសកម្មភាពស្ថាបនាយ៉ាងលឿន។

ព្រះសាស្តាﷺបានរង់ចាំអស់បីថ្ងៃ ទើបអ៊ាលីصلوات الله عليه والسلام កនភ័ក្តីនិងពំនឹងរបស់ព្រះអង្គﷺ បានមករកព្រះអង្គﷺឯគូ៏បាអ៍(قباء)ក្រោយពីបានបំពេញបេសកកម្មព្រះអង្គصلوات الله عليه والسلامយ៉ាងក្លាហាន ៕

# ២. ក្រោយហ៊ិចរ៉ោះត៍

## រដ្ឋអ៊ីស្លាមដំបូងបង្អស់

ពេលដែលព្រះសាស្តាﷺនិងបក្សពួកភៀសខ្លួនរបស់ព្រះអង្គបានចូលមកក្នុងនគរម៉ាឌីណាស់ ជាព្រឹត្តិការណ៍ផ្តាច់ព្រ័ត្រមួយក្នុងសាសនាអ៊ីស្លាមគឺៈ ជាហ៊ិចរ៉ោះត៍ធំ ពោលគឺ ការភៀសខ្លួនដោយស្ម័គ្រចិត្តដើម្បីគាប់ព្រះហឫទ័យអល់ឡោះហ្វ៍ﷻ។

ពួកមុស្លីមស្រុកម៉ាក់កាស់ដឹងច្បាស់នូវតម្លៃព្រឹត្តិការណ៍នេះ។ ពួកគេដណ្តើមគ្នាយកកិត្តិយសទទួលព្រះសាស្តាﷺនៅឯគេហដ្ឋានខ្លួន។ តែព្រះសាស្តាﷺបានបញ្ចប់ការជជែកគ្នាយ៉ាងរហ័ស ដោយប្រាប់អ្នកទទួលរាក់ទាក់ទាំងអស់ថាមេអូដ្ឋព្រះអង្គ ដែលនៅក្រោមព្រះបញ្ជាអល់ឡោះហ្វ៍ﷻនោះ នឹងជ្រើសរើសដោយខ្លួនវាផ្ទាល់នូវអនាគតកន្លែងស្នាក់នៅជាបណ្តោះអាសន្នរបស់វា។ នៅចំពោះមុខបណ្តាអ្នកទទួលរាក់ទាក់អន្ទះអន្ទែង មេអូដ្ឋបានមកឈប់ពីមុខបុរសអាន់ស្វារម្នាក់ឈ្មោះ អាប៊ូ-អៃយូប ដែលមានកិត្តិយសជាបាហុនកៈទទួលភ្ញៀវថ្លៃថ្នូរបំផុតក្នុងទូទាំងភពផែនដែនចក្រវាល។

បន្ទាប់ពីព្រះសាស្តាﷺបានមកដល់ម៉ាឌីណាស់ នគរនេះស្គាល់សន្តិភាពជាគ្រាដំបូងបង្អស់តាំងពី ១២០ ឆ្នាំមកហើយ។ ក្នុងអំឡុងពេល ១២០ ឆ្នាំនេះ កុលសម្ព័ន្ធពីរគឺ កុលសម្ព័ន្ធអៅស៍ (بنو اوس) និងកុលសម្ព័ន្ធខាស្ស៊រ៉ចុ (بنو خزرج) ប្រហែកប្រហូរគ្នាឥតប្រណី។ ចំណែកឯកុលសម្ព័ន្ធយ៉ាហ៊ូឌីជិតខាងទាញយកផលប្រយោជន៍ពីការវាយប្រហារគ្នានេះ ថែមទាំងមិនអាក់ខានបង្កាត់ភ្លើងសង្គ្រាមរាល់ពេលដែលវារៀបរលត់៕

ដូច្នេះ ហ៊ិចរ៉ោះត៍(ការភៀសខ្លួន)បានធ្វើឲ្យកុលសម្ព័ន្ធទាំងពីរស្ងប់ហើយបានលុបចោលនូវតួល្ខោនកំណាចរបស់អ្នកជិតខាងយ៉ាហ៊ូឌីរបស់ខ្លួន។ រាល់ពេលដែលឯកភាពពួកអាន់ស្វារត្រូវការរួមគំនិតក្បត់ថ្មីមួយគំរាមកំហែង ព្រះសាស្តាﷺធ្វើអន្តរាគមន៍ដើម្បីនាំសន្តិភាពត្រឡប់មកវិញ។

ពួកមុស្លីមភៀសខ្លួននៅម៉ាឌីណាស់មានចំនួនច្រើនឡើងៗ ហើយច្រើនតែអភ័ព្វនិងទ័លក្របន្ទាប់ពីត្រូវពួកពហុទេពនិយមរឹបអូសយកទ្រព្យ។ ព្រះសាស្តាﷺបានរាប់រកពួកអ្នកមកដល់ថ្មីនេះជាបងប្អូន ជាមួយពួកអាន់ស្វារហើយព្រមរំលែកទ្រព្យរបស់ខ្លួនឲ្យទៅពួកគេ។

ការរួបរួមគ្នារបស់ពួកអាន់ស្វារជាមួយពួកភៀសខ្លួនដែលហៅថាមូហាយ៉ីរីន (المهاجرين) ដើម្បីសព្វព្រះហឫទ័យអល់ឡោះហ្វ៍ﷻ បានធ្វើឲ្យសហគមន៍មុស្លីមដំបូងបង្អស់កកើតឡើងក្នុងគោលដៅធ្វើឲ្យសារនៃសាសនាអ៊ីស្លាមខាងសង្គមកិច្ចលេចឡើងជារូបជារាង៕

## ការផ្លាស់ប្តូរទិសនមស្ការ(ស្ហ៊ឡាត់)

កាលព្រះសាស្តាﷺនៅឯម៉ាក់កាស់ ទិសសម្រាប់បំពេញនមស្ការ(គីបឡាត់)គឺបែរទៅរកម៉ាស់យ៉ីដ អាល់-

អាក់ស្វា(المسجد الاقصى)ដែលស្ថិតនៅឯនគរអាល់-គុដុស៍(القدس នគរយេរូសាឡឹម)។

ក្រោយពីហ៊ិច្ជរ៉ោះត៍ ពួកមុស្លីមនៅតែបំពេញនមស្ការដោយបែរទៅរកគិប្លាត់ដដែល។ ទង្វើនេះបានជួយជម្រុញពួកយ៉ាហ៊ូឌីឲ្យចំអន់ពួកគេថា ធ្វើនមស្ការដោយបែរទៅរកទិសនេះជាការសារភាពថាសាសនាយ៉ាហ៊ូឌីដែលពួកយ៉ាហ៊ូឌីប្រកាន់យកនោះជាសាសនាពិតប្រាកដ។ តែស្ថានភាពនេះមានថិរវេលាមិនលើសពីដប់ប្រាំពីរខែទេ។ បន្ទាប់ពីនោះ អល់ឡោះហ៍ﷻបានព្រះបញ្ជាមកឲ្យផ្លាស់គិប្លាត់ ឲ្យបែរទៅរកម៉ាស់យ៊ីដុពិសិដ្ឋនៃនគរម៉ាក់កាស់។

ការផ្លាស់ប្តូរគិប្លាត់ជាដំណឹងអាក្រក់សម្រាប់ពួកយ៉ាហ៊ូឌីនៃនគរម៉ាឌីណាស់។ ពួកគេគិតក្នុងចិត្តថា អ្នកណាបានយកគិប្លាត់នោះចេញពីកន្លែងដើមរបស់វា? ពួកអសទ្ធាទាំងនេះទំនងជាមិនដឹងសោះថា ព្រឹត្តិការណ៍នេះមិនមែនអ្វីផ្សេងពីការល្បងពិសោធន៍ជំនឿសម្រាប់ពួកមុស្លីមនោះទេ។

## ការការពារសាសនាអ៊ីស្លាម

### ១-សមរភូមិបាដ់រ៍

ដើម្បីការពារម៉ាឌីណាស់ពីការលុកលុយឬការក្បត់ ព្រះសាស្តាﷺបានធ្វើកតិកាសញ្ញានិងសន្ធិសញ្ញាជាមួយបណ្តាកុលសម្ព័ន្ធដែលនៅក្បែរនគរមុស្លីម។

ដើម្បីយកមកវិញនូវទ្រព្យមួយចំនួនដែលពួកអសទ្ធាបានរឹបយកនៅឯម៉ាក់កាស់ និងដើម្បីរំដោះខ្លួនពីអំណាចកុលសម្ព័ន្ធគូរ៉យស៍ក្នុងចំណោមពួកអារាប់ ព្រះសាស្តាﷺបានរៀបចំការលុកលុយទៅលើក្បួនទូរចរជំនួញរបស់ពួកមេដឹកនាំពហុទេពនិយមនៃនគរម៉ាក់កាស់។

ដូច្នេះឯងដែលការប្រយុទ្ធដោយអាវុធរវាងពួកមុស្លីម និងពួកពហុទេពនិយមបានកើតឡើងនៅជិតខាងអណ្តូងបាដ់រ៍។ នេះគឺសមរភូមិបាដ់រ៍ដ៏ល្បីល្បាញដែលបាននាំមកឲ្យពួកមុស្លីមនូវកេរ្តិ៍ឈ្មោះល្អក្នុងចំណោមពួកអារាប់។

ពិតមែន ទោះបីគ្រឿងប្រដាប់របស់ពួកពហុទេពនិយមក្នុងសមរភូមិនេះច្រើនជាងគ្រឿងប្រដាប់របស់ពួកមុស្លីមបីដងក៏ដោយ ក៏ជ័យជំនះរបស់ព្រះសាស្តានិងបណ្តាសាវកព្រះអង្គﷺជាជ័យជំនះមួយដ៏សម្បើម។ មេដឹកនាំធំៗរបស់ពួកពហុទេពនិយមនៃនគរម៉ាក់កាស់ច្រើននាក់បានស្លាប់ក្នុងសមរភូមិនេះ។



## ២-សមរភូមិអ៊ូហ៊ុដ

បន្ទាប់ពីបានទទួលបរាជ័យនៅឯសមរភូមិបាដ់រ៍ ពួកគូរ៉យ៉ស្ម៍ក្រេវក្រោធអនេកហើយគិតនឹងសងសឹក។ អាប៊ូ ស៊ុហ្វយ៉ាន មេដឹកនាំថ្មីរបស់ពួកគេបានរៀបចំសមរភូមិថ្មីមួយភ្លាម ដោយហាមមិនឲ្យពួកស្រ្តីគូរ៉យ៉ស្ម៍បង្ហាញនូវការកាន់មរណទុក្ខ ដរាបណាមិនទាន់បានសងសឹកឲ្យបងប្អូនពួកគេដែលបានស្លាប់នោះជាមុនសិនទេ។ អាប៊ូ ស៊ុហ្វយ៉ានចង់ញុះញង់ឲ្យមានគំនុំនិងចង់បង្កាត់ភ្លើងកំហឹងពួកគូរ៉យើស្ម៍ឲ្យកាន់តែឆេះខ្លាំងឡើង

ដោយសារបម្រាមនេះ។

ម្ខាងទៀត ពួកយ៉ាហ៊ូឌីបារម្ភខ្លាំងដោយសារជ័យជំនះរបស់ពួកមុស្លីម។ ពួកគេព្យាយាមសាកល្បងជំរុញកុលសម្ព័ន្ធគូរ៉យស្ទ៍ឲ្យសងសឹកវិញ។ ដូច្នេះ មេដឹកនាំពួកគេម្នាក់ឈ្មោះ កាអ៊្មប់ អ៊ីបន៍ អាល់-អាស្ទ៍រ៉ហ្វ (كعب بن الاشرف) ហើយដែលជាកវីមួយរូបដែរ ត្រូវចាត់បញ្ជូនទៅកាន់នគរម៉ាក់កាស្ទ៍ដើម្បីសូត្រកំណាព្យជំរុញឲ្យសងសឹកឲ្យពួកគូរ៉យស្ទ៍ស្តាប់។

ពួកគូរ៉យស្ទ៍បានបើកសម័យប្រជុំមួយនៅឯទីប្រជុំពិភាក្សារកវិធីងាយស្រួលក្នុងសមរភូមិខាងមុខ។ ពួកគេបានសម្រេចចិត្តវាយលុកនគរម៉ាឌីណាស្ទ៍ ហើយបានគ្រោងទុកសម្រាប់សមរភូមិនេះនូវថវិការដ៏សម្បើមដែលមានចំនួនហាសិបពាន់ឌីណារ៍ ហើយពួកគេមិនខានសូមជំនួយពីសម្ព័ន្ធមិត្តពួកគេឡើយ។

ទ័ពពួកអសទ្ធាមានរេហ៍ពលលើសពីបីពាន់នាក់។ គំនុំគុំកួនជាកម្លាំងចិត្តពួកគេ ពួកគេគិតតែសងសឹកតែម្យ៉ាង។

លុះពួកគេចេញដំណើរទៅឯម៉ាឌីណាស្ទ៍ដោយព្យាយាមរក្សារឿងសម្ងាត់នេះ ដំណឹងយុទ្ធការនេះបានលេចឮទៅដល់ព្រះសាស្តាﷺតាមរយៈសំបុត្រមួយច្បាប់ពីអ៊្មប់បាស់ ឪពុកមាព្រះអង្គﷺ ដែលរស់នៅឯនគរម៉ាក់កាស្ទ៍ដោយលាក់ជំនឿអ៊ីស្លាមរបស់លោក។

អាប៊ូ ស៊ុហ្វយ៉ានជាមេបញ្ជាការក្នុងយុទ្ធការនេះ។ ទ័ពសេះនៅក្រោមបញ្ជាការរបស់ខ៉ូលិដ្ អ៊ីបន៍ អាល់-វ៉ាលីដ្(خالد بن الوليد)។ ខណៈដែលពួកអសទ្ធាសំដៅមកកាន់ម៉ាឌីណាស្ទ៍ ពួកមុស្លីម ដែលបានទទួលដំណឹងហើយ បានប្រជុំគ្នានៅក្នុងម៉ាស់យ៉ីដ្ ហើយបានសម្រេចចិត្តចេញទៅប្រឈមមុខពួកសត្រូវនៅឯខាងក្រៅនគរ។

ពួកគេប្រមូលគ្នាបានប្រមាណមួយពាន់នាក់។ ពួកគេមួយភាគបីបានបង្ហាញឲ្យឃើញនូវពុតត្បុតដោយបកក្រោយវិញមុនចាប់ផ្តើមប្រយុទ្ធ។ តែករណីនេះមិនបានធ្វើឲ្យខូចកម្លាំងចិត្តពួកមុស្លីមទេដែលអន្ទះអន្ទែងចង់ស្លាប់ដើម្បីអល់ឡោះហ្ ﷻ។ ព្រះសាស្តានិងបណ្តាអ្នកភ័ក្តីបានចូលទៅជួបពួកសត្រូវដែលមានចំនួននិងមានគ្រឿងប្រដាប់ច្រើនជាងពួកគេបួនដង។

ព្រះសាស្តាបានជ្រើសរើសយកជើងភ្នំអ៊ូហ៊ូដ្ជាទីតាំងសំខាន់ នៅក្បែរម៉ាឌីណាស្ទ៍។

ទ័ពទាំងពីរបានជួបគ្នាថ្ងៃសៅរ៍ទី ៧ ខែស្ទាវ៉ាល់ ឆ្នាំទី ៣ សករាជហ៊ិចរ៉ោះត៍។ ពួកមុស្លីមនៅរវាងភ្នំនិងទ័ពសត្រូវ។

ដើម្បីទប់ស្កាត់ការវាយប្រហារមកលើខាងក្រោយទ័ពមុស្លីម ព្រះសាស្តាﷺបានបញ្ជាឲ្យខ្មាន់ធ្នូចំនួនហាសិបនាក់នៅកាន់ទួលមួយដែលលេចត្រដែតលើផ្លូវគ្រោះថ្នាក់តែមួយ។

ព្រោះតែទីតាំងរបស់ពួកខ្មាន់ធ្នូសំខាន់បំផុត បានជាព្រះសាស្តាﷺដាក់បញ្ជាយ៉ាងដាច់ខាតកុំឲ្យពួកគេចោលទីតាំងនេះ ទោះជាមានមូលហេតុអ្វីក៏ដោយ។

លទ្ធផលនៃការប្រយុទ្ធលើកដំបូងរវាងទ័ពទាំងពីរគឺ ពួកអសទ្ធាបានទទួលបរាជ័យយ៉ាងជូរចត់។ ពួកគេ

រត់ចាលលានប្រយុទ្ធ ពួកមុស្លីមដេញតាមពួកគេ។

កងខ្មាន់ធ្នូដែលបានឃ្លាំមើលការប្រយុទ្ធពីលើទួលស្មានថាការប្រយុទ្ធគ្នានេះចប់ស្រេចហើយ ហើយគិតថា ពួកគេមានសិទ្ធិចុះមកចូលរួមជាមួយបងប្អូនយុទ្ធជនរបស់ពួកគេ ដើម្បីប្រមូលយកទ្រព្យឈ្លើយដែលពួកទទួលបរាជ័យនោះបានបោះបង់ចោល។

តែខ៊ំលិដ អ៊ីបន៍ អាល់-វ៉ាលីដ មេទ័ពសេះ បានឃ្លាំមើលព្រឹត្តិការណ៍នេះពីចម្ងាយ។ លុះគាត់បានឃើញថា ខ្សែត្រៀមក្រោយរបស់ពួកមុស្លីមត្រូវចំហចោលដោយកងខ្មាន់ធ្នូដែលបានចោលទីតាំងខ្លួន គាត់ក៏បានដឹកនាំការវាយឆ្មក់តាមផ្លូវនេះ បង្កឲ្យមានការច្របូកច្របល់ក្នុងជួរមុស្លីម បានធ្វើឲ្យស្ថានភាពសមរភូមិប្រែក្រឡាប់។

មុស្លីមភាគច្រើនមិនមានសមត្ថភាពល្មមនឹងបទពិសោធន៍ថ្មីមួយនេះទេ។ ស្មានថាព្រះសាស្តាﷺបានចូលទិវង្គតពេលទ័ពសេះបានវាយលុកមកនោះហើយ ពួកគេបានបែកខ្ញែកគ្នាគ្រប់ទិសទី ទុកឲ្យយុទ្ធជនក្លាហាននិងភ័ក្តីមួយចំនួនតូចទប់ទល់ការប៉ះទង្គិចនិងរារាំងពួកអសទ្ធាមិនឲ្យចូលដល់ព្រះសាស្តាﷺទេ។

នៅក្នុងដំណាក់ការផ្តាច់ព្រ័ត្រនិងប្រកបដោយគ្រោះថ្នាក់នេះ អ៊ាលី សាវកភ័ក្តី បានការពារព្រះសាស្តាﷺយ៉ាងក្លាហាន ហើយបានបញ្ចប់ការប្រយុទ្ធដោយបានជួយជីវិតពួកអ្នកការពារមួយចំនួនតូចដែលបានជួបជុំគ្នាក្នុងស្ថានភាពមាំមួនដើម្បីរៀបចំការវាយតបវិញ។

ពេលពួកអសទ្ធាបានឃើញថាពួកមុស្លីមអាចឈ្នះជាលើកទីពីរ ពួកគេបានរត់ចោលលានប្រយុទ្ធ។ ពួកគេបានលួងចិត្តខ្លួនឯងដោយផ្អែកទៅលើចំនួនសត្រូវមុស្លីមដ៏ច្រើនដែលខ្លួនបានសម្លាប់។

សមរភូមិអ៊ូហ៊ុដជាមេរៀនធំមួយសម្រាប់មុស្លីមទូទៅ។ ពិតប្រាកដណាស់ ប្រសិនបើខ្មាន់ធ្នូបានគោរពបញ្ជាព្រះសាស្តាﷺ ការប្រយុទ្ធច្បាស់ជាមិនបានផ្លាស់ប្តូរស្ថានភាពឡើយ។

ម្យ៉ាងទៀត ការប្រញាប់រត់យករូចខ្លួនរបស់ពួកមុស្លីមភាគច្រើន ជាពិសេសបុគ្គលល្បីល្បាញក្នុងចំណោមពួកមូហាយ៉ីរីន ដែលគិតថានឹងទទួលបរាជ័យចាប់តាំងពីពេលព្រះសាស្តាﷺបានប្រកាសហៅឲ្យទប់ទល់មកម្ល៉េះនោះ សឲ្យឃើញថាមុស្លីមភាគច្រើនស្រឡាញ់ជីវិតណាស់។

ព្រឹត្តិការណ៍នេះបង្ហាញឲ្យឃើញថាអង្គភាពមុស្លីមដ៏ខ្ចីនេះទន់ខ្សោយណាស់ ហើយមានតែសមរភូមិលំដាប់ថ្នាក់នេះទេដែលអាចបើកឲ្យគេឃើញភាពទន់ខ្សោយនេះ និងកត់ត្រាវាទុកក្នុងប្រវត្តិសាស្ត្របាន។

## ៣-សមរភូមិខាន់ដាក់(الخندق)

ព្រឹត្តិការណ៍នានា សង្គមអ៊ីស្លាមនិងសាសនាអ៊ីស្លាមនៃគនរម៉ាឌីណាស់ដែលកាន់រឹងប៉ឹងឡើងបន្តិចម្តងៗនោះជាប្រភពនៃសេចក្តីព្រួយបារម្ភឥតស្រាកស្រាន្តរបស់ពួកយ៉ាហ៊ូឌីនៃនគរម៉ាឌីណាស់។ ពួកយ៉ាហ៊ូឌីខិតខំប្រមែប្រមូលកម្លាំងពហុទេពនិយមអារ៉ាប់ក្រោមការឧបត្ថម្ភគាំទ្ររបស់ពួកគូរ៉យស្ ដើម្បីប្រយុទ្ធជាគ្រាចុងក្រោយបង្អស់ទល់នឹងពួកមុស្លីម។

ការខិតខំប្រឹងប្រែងរបស់ពួកគេមិនអត់លទ្ធផលទេ។ ពិតណាស់ កុលសម្ព័ន្ធអារ៉ាប់អសទ្ធាបានរួបរួមគ្នាជាសម្ព័ន្ធភាពដ៏ធំមួយ ដើម្បីប្រជុំជាកងទ័ពធំមួយដែលមានវរេហ៍ពល ១២០០០ នាក់។ ចលនាទ័ពឆ្ពោះទៅឯនគរម៉ាឌីណាស់បានចាប់ផ្ដើម។

ពលសេះរបស់កុលសម្ព័ន្ធជិតខាងរបសស់កុលសម្ព័ន្ធឃូស្សាអ៊ាស់(خزاعة) បាននាំដំណឹងវាយប្រហារដែលជិតកើតឡើងទៅប្រាប់ពួកមុស្លីមនៃនគរម៉ាឌីណាស់។ ព្រះសាស្ដាﷺបានកោះហៅពួកមុស្លីមប្រជុំដើម្បីពិភាក្សារិះរកមធ្យោបាយការពារនគរ។

គេបានមូលមតិគ្នាព្រមទទួលយកយោបល់របស់សាល់ម៉ាន អាល់-ហ្វារស៊ីដែលតម្រូវឲ្យជីកប្រឡាយជុំវិញនគរ ហើយបានចាប់ផ្ដើមបំពេញកិច្ចការភ្លាម។

ប្រឡាយប្រវែង ១២ គីឡូម៉ែត្រ ជម្រៅ ៥ ម៉ែត្រ និងទទឹង ៦ ម៉ែត្រត្រូវបានជីកហើយស្រេច ពេលទ័ពបច្ចាមិត្តបានព័ទ្ធនគរ។

ពួកអសទ្ធាភ្ញាក់ផ្អើល មិនដឹងជាធ្វើអ្វី និងធ្វើយ៉ាងណាទេ ព្រោះមានប្រឡាយជ្រៅនៅពីមុខពួកគេដែលប្រកបដោយគ្រោះថ្នាក់ក្នុងការឆ្លងកាត់។ មិនតែប៉ុណ្ណោះទេ នៅពីក្រោយប្រឡាយនេះមានរបាំងការពារទ័ពដែលមានខ្មាន់ធ្នូប្រុងជើងការជាស្រេចទៀតផង។

សរុបសេចក្ដី ស្ថានភាពនេះគួរឲ្យអៀនខ្មាសសម្រាប់អ្នកវាយប្រហារ ដែលរហូតមកដល់ពេលនេះជឿជាក់មាំថានឹងមានជ័យជំនះដោយផ្អែកទៅលើចំនួនវរេហ៍ពលនិងគ្រឿងប្រដាប់ដ៏ច្រើននោះ។

ការឡោមព័ទ្ធម៉ាឌីណាស់បានប្រព្រឹត្តទៅពីរបីថ្ងៃទៀត។ ក្នុងរយៈពេលនេះ ពួកមុស្លីមព្រួយបារម្ភគ្រប់យ៉ាង។ ពួកគេមិនត្រឹមតែត្រូវឃ្លាំមើលប្រឡាយមួយមុខទេ ថែមទាំងត្រូវឃ្លាំមើលព្រំប្រទល់ជាមួយអតីតសម្ព័ន្ធមិត្តរបស់ពួកគេដែលបានក្បត់ពួកគេ គឺកុលសម្ព័ន្ធយ៉ាហ៊្វូឌី បានូ គូរ៉យស្មោះត៍(بنو قريظة)។

ពិតណាស់ បន្ទាប់ពីកុលសម្ព័ន្ធនេះបានក្បត់និងបានផ្ដាច់សម្ព័ន្ធភាពជាមួយព្រះសាស្ដាﷺ ពួកមុស្លីមត្រូវបម្រុងទុកនូវរេហ៍ពលមិនតិចជាង ៥០០ នាក់ទេដើម្បីឃ្លាំមើលបនក្បត់ទាំងនេះនិងរារាំងពួកគេមិនឲ្យលួចវាយប្រហារ។

ពួកឡោមព័ទ្ធបានសាកល្បងវាយទម្លុះខ្សែត្រៀមការពារពួកមុស្លីមជាច្រើនលើកដើម្បីចូលទៅក្នុងនគរ តែមិនបានសម្រេចទេ វៀរលែងតែការវាយលុកមួយលើក ដឹកនាំដោយពលសេះដ៏ល្បីល្បាញម្នាក់ដែលពួកមុស្លីមញញើត។ បុគ្គលនេះមានឈ្មោះថា អ៊ុាំរូ អ៊ីបនូ អ៊ុាប់ឌុល-វ៉ាដ់ ដែលគេស្គាល់ថាជាវីរបុរសរបស់ពួកអារ៉ាប់ ហើយជាពលសេះមួយរូបដែលមិនចេះបរាជ័យឡើយនៅទូទាំងឧបទ្វីប។

ពិតណាស់ អ៊ុាំរូនិងពលសេះប្រាំរូបទៀតបានវាយទម្លុះខ្សែត្រៀមជួរមុខរបស់ភាគីមុស្លីម។ គាត់បានមកឈប់នៅកណ្ដាលលានប្រយុទ្ធ បានបបួលភាគីមុស្លីមប្រយុទ្ធតតួមួយទល់នឹងមួយដោយអាកប្បកិរិយាចំអក។

ពលមុស្លីមមើលមុខគ្នា អ្នកក្លាហានជាងគេមិនហ៊ានទទួលការបបួលប្រកួតទេ មិនមែនព្រោះតែខ្លាចស្លាប់ទេ តែព្រោះតែខ្លាចថាបរាជ័យរបស់ខ្លួននឹងធ្វើឲ្យភាគីមុស្លីមបាក់ទឹកចិត្ត។

អ៊ុាលីصلوات الله عليه والسلامបានជួយយោងស្ថានភាពម្ដងទៀត ដោយព្រមទទួលការបបួលប្រកួត។ អស់រយៈពេលតែបន្តិចប៉ុណ្ណោះ ភាគីមុស្លីមបានធូរអារម្មណ៍ពេលបានឃើញអ៊ុាំរូលំក្រោមការវាយប្រហាររបស់អ៊ុាលីصلوات الله عليه والسلام។

ជនអសទ្ធាប្រាំនាក់ទៀតបានរត់ប្រាសអាយុ។ អ៊ាលីعليه والسلام صلوات اللهបានតាមទាន់ពួកគេម្នាក់នៅក្នុងប្រឡាយ ហើយបានសម្លាប់បុគ្គលនោះ។



ការប្រយុទ្ធតតួនេះបានលើកកម្លាំងចិត្តភាគីមុស្លីម។ ចំណែកឯទឹកចិត្តភាគីអសទ្ធាចាប់ផ្ដើមអន់ថយ ជាពិសេស ក្រោយពីបានទទួលបរាជ័យក្នុងការល្បងវាយលុករបស់ពលសេះរបស់ខ៊ំលិដ្ អ៊ីបន៍ អាល់-វ៉ាលីដ្ និងក្រោយពីបានឮពាក្យចចាមអារ៉ាមផ្សាយចេញពីពួកមុស្លីមដែលបានលបចូលទៅក្នុងចំណោមពួកគេ ថាបក្សសម្ព័ន្ធយ៉ាហ៊ូឌីរបស់ពួកគេបានធ្វើកតិកាសញ្ញាជាមួយព្រះសាស្ដាﷺហើយ។

ខណៈដែលពាក្យចចាមអារ៉ាមនេះខ្ចរខ្ចាយ កុលសម្ព័ន្ធអារ៉ាប់មួយចំនួនតូចដែលចងសម្ព័ន្ធជាមួយពួកគូរ៉យស្ទ៍បានចាប់ផ្តើមសួរខ្លួនឯងថាតើពួកគេបានជ្រើសរើសយកចំណែកល្អឬទេ។ ពួកគេព្រមទទួលសេចក្តីស្នើរបស់ព្រះសាស្តាﷺដែលសូមឲ្យពួកគេដកថយទៅកាន់ទឹកដីពួកគេវិញ ព្រះអង្គﷺនឹងប្រគល់ឲ្យពួកគេមួយភាគបីនៃកសិផលលមើរបស់នគរម៉ាឌីណាស់។

តែការប្តេជ្ញាចិត្តរបស់អាប៊ូ ស៊ុហ្វយ៉ាន មេបញ្ជាការទូទៅរបស់បក្សសម្ព័ន្ធអារ៉ាប់ ត្រូវខូចពេល អល់ឡោះហ៊្វ ﷻបានធ្វើអន្តរាគមន៍ដោយចាត់បញ្ជូនមកនូវខ្យល់ចម្លែក ដែលបង្កឲ្យកើតមាននូវភាពច្របូកច្របល់ និងសេចក្តីបារម្ភក្នុងចំណោមពួកបដិសេធសទ្ធា។

ដោយឃើញថាស្ថានការណ៍មនុស្សនិងស្ថានការណ៍ធម្មជាតិមិនហុចអំណោយផល ក្នុងការបន្តការឡោមព័ទ្ធនោះ ទើបអាប៊ូ ស៊ុហ្វយ៉ានបានចេញបញ្ជាឲ្យដកថយវិញ។ នេះគឺអវសានរបស់វិបត្តិធំមួយដែលបានគម្រាមអាយុជីវិតរបស់អង្គភាពអ៊ីស្លាមដំបូងបង្អស់ក្នុងប្រវត្តិសាស្ត្រ។

## ៤-ការធ្វើទណ្ឌកម្មពួកបនក្បត់

បន្ទាប់ពីពួកបក្សសម្ព័ន្ធអសទ្ធាបានដកថយទៅ ព្រះសាស្តាﷺបានបែរមករកពួកបនក្បត់ដែល នៅពេលឡោមព័ទ្ធភាគីមុស្លីមនោះ ជាទ័ពស្រួចមួយនៅក្រោយខ្នងភាគីមុស្លីម គឺបានូ គូរ៉យស្ឡោះត៍(بنو قريظة)។

ព្រះសាស្តាﷺបានបញ្ជាឲ្យឡោមព័ទ្ធបន្ទាយពួកគេ។ ការឡោមព័ទ្ធនេះបានប្រព្រឹត្តទៅអស់រយៈពេល ២៥ ថ្ងៃ។ នៅទីបំផុតពួកបានូ គូរ៉យស្ឡោះត៍ព្រមចុះចាញ់ និងព្រមទទួលការវិនិច្ឆ័យរបស់អតីតមិត្តរបស់ពួកគេ គឺមេដឹកម្នាក់របស់ពួកអាន់ស្វារដែលមានឈ្មោះថា សាអ៊ុាដ់ អ៊ីបន៍ ម៉ាអ៊ុាស់ (سعد ابن معاذ)។

សាអ៊ុាដ់ជាបុគ្គលមានសទ្ធាស៊ប់ចិត្ត លោកវិនិច្ឆ័យតាមតែច្បាប់អល់ឡោះហ៊្វﷻមួយមុខ។ ព្រះសាស្តាﷺយល់ស្របតាមការកាត់ទោសត្រឹមត្រូវរបស់លោក គឺៈ តម្រូវឲ្យប្រហារជីវិតពួកបនក្បត់ទាំងអស់ លើកលែងតែស្ត្រីនិងក្មេង។

ជីវិតអប្រិយរបស់ពួកយ៉ាហ៊្វូឌីបានចប់បែបនេះឯងនៅឯនគរម៉ាឌីណាស់ ក្រោយពីបានក្បត់និងបានរៀបផែនការសម្ងាត់ដ៏យូរមកហើយប្រឆាំងភាគីមុស្លីម។ ចាប់តាំងពីថ្ងៃដំបូងនៃសករាជហ៊ិជ្រ៉ោះត៍មកម្ល៉េះ កុលសម្ព័ន្ធឯទៀតបានក្បត់ភាគីមុស្លីម ដូចជាកុលសម្ព័ន្ធបានូ កូយ៉ន្ញ៉ក៏អ៊ុ (بنو قينقاع) និងបានូ អាន់ណាឌៀរ (بنو النضير) ដែលកាលនោះ ត្រូវបណ្តេញចេញពីនគរម៉ាឌីណាស់ហើយ។

## ៥-យុទ្ធសន្តិភាពហ៊ូដៃប៊ីយ៉ាស់(صلح الحديبية)

កេរ្តិ៍ឈ្មោះរបស់ភាគីមុស្លីមនិងសាសនាអ៊ីស្លាមកាន់តែល្បីរន្ទឺខ្លាំងឡើងៗ ក្នុងចំណោមកុលសម្ព័ន្ធអារ៉ាប់បណ្តាលឲ្យសំណាក់បានី គូរ៉យស្ទ៍ទើសចិត្តឡើងៗព្រោះតែឃើញថាខ្លួនបាត់បង់អំណាចបន្តិចម្តងៗ។

ក្នុងស្ថានភាពនេះ ព្រះសាស្តាﷺបានសម្រេចព្រះហឫទ័យបោះជំហានមួយយ៉ាងធំក្នុងការផ្សាយព្រះសាសនាអល់ឡោះហ៊្វﷻ។ នៅក្នុងខែស៊ុល-ក៏អ៊ីដាស់(ذو القعدة) ឆ្នាំទី ៦ សករាជហ៊ិជ្រ៉ោះត៍ ព្រះអង្គﷺបានប្រកាសប្រាប់បណ្តាសាសនិកភ័ក្តីរបស់ព្រះអង្គﷺ អំពីការចេញដំណើរទៅបំពេញពិធីបូជនីយេសចរណ៍(ពិធី

ហាច្ចយ៍)នៅឯនគរម៉ាក់កាស់ដោយឥតមានគោលបំណងធ្វើសង្គ្រាមទល់ភាគីគូរ៉យស្ទ៍ទេ។

ភាគីមុស្លីមដែលតាមព្រះសាស្តាﷺនោះមានចំនួន ១៤០០ នាក់។ ពួកគេបានឆ្ពោះទៅកាន់នគរម៉ាក់កាស់ ដោយពុំមានគម្រោងធ្វើសង្គ្រាមទេ មានជាប់នឹងខ្លួនតែអាវុធសាមញ្ញសម្រាប់ធ្វើដំណើរទេ។ លុះពួកគេបាន ទៅដល់កន្លែងមួយដែលហៅថា ស៊ុលហ៊ុឡៃហ្វាស់(ذو الحليفة) ពួកគេបានគ្រងសំលៀកបំពាក់អ៊ិះហ្រ៊ាម(إحرام គឺ សំលៀកបំពាក់របស់អ្នកកាន់ត្រណម) ដែលជាទង្វើប្រារព្ធក្នុងពិធីបូជនីយេសចរណ៍(ពិធីហាច្ចយ៍)។ នៅក្នុងពិធី នេះ បូជនីយេសក៍(អ្នកបំពេញពិធីបូជនីយេសចរណ៍)ស្លៀកពាក់សំលៀកបំពាក់ពិសេស ហើយត្រូវតមធ្វើទង្វើ មួយចំនួនដែលត្រូវហាមខណៈពួកគេគ្រងសំលៀកបំពាក់នេះ។



សកម្មភាពរបស់ភាគីមុស្លីមជះឥទ្ធិពលទៅលើពួកអារ៉ាប់នៃឧបទ្វីប។ ដោយសារការបង្ហាញឲ្យឃើញសេចក្ដីក្លាហាននិងភក្ដីភាពនេះ ពួកអារ៉ាប់បានវាយតម្លៃពួកគេកាន់តែខ្ពស់ឡើងៗ។ ម្យ៉ាងទៀត ព្រឹត្តិការណ៍នេះធ្វើឲ្យភាគីគូរ៉យ៉ស្ញ័ភ័យ។ ពួកពហុទេពនិយមនៃនគរម៉ាក់កាស់ដែលភ័យស្លន់ស្លោនោះមិនដឹងជាធ្វើអ្វីល្អទេ ពួកគេបានស្បថចំពោះរូបបដិមាទាំងឡាយថានឹងមិនបណ្ដោយឲ្យភាគីមុស្លីមចូលមកក្នុងម៉ាក់កាស់ទេ។

ខណៈនោះ ខ៏លិដ្ អ៊ីបនូ អាល់-វ៉ាលីដ្ធនិងពលសេះពីររយនាក់បានចេញទៅប្រឈមនឹងបូជនីយេសក៍មុស្លីមក្នុងបំណងបង្កហេតុ។

ព្រះសាស្ដាឪ្ចបានយល់ន័យសកម្មភាពរបស់ខ៏លិដ្ធនិងទ័ពសេះរបស់គេ។ ទោះជាយ៉ាងណាក៏ដោយ ព្រះអង្គﷺត្រូវចៀសវាងការប៉ះទង្គិចគ្នាជាមួយទ័ពគូរ៉យ៉ស្ញ ដូច្នេះព្រះអង្គﷺបានដូរផ្លូវ ហើយបានមកឈប់នៅឯកន្លែងមួយដែលហៅថា ហ៊ុដៃ្ធប៊ីយ៉ាស់។

ព្រះអង្គﷺបានចាត់បញ្ជូនអ្នកនាំសារម្នាក់ទៅកាន់នគរម៉ាក់កាស់ ដើម្បីបញ្ជាក់ប្រាប់ពួកគេថា ព្រះអង្គﷺ មកនេះមិនមែនក្នុងគោលបំណងបង្កហេតុទេ ព្រះអង្គﷺមកបំពេញពិធីបូជនីយេសចរណ៍តែមួយមុខទេ។

ខណៈដែលអ្នកនាំពាក្យព្រះសាស្ដាﷺត្រូវពួកពហុទេពនិយមនៃនគរម៉ាក់កាស់ ប្រព្រឹត្តលើដោយមិនសមរម្យ ភាគីមុស្លីមបានប្រជុំគ្នានៅជុំវិញព្រះបរមគ្រូﷺពួកគេនៅក្រោមដើមឈើមួយដើម ហើយបានស្បថចំពោះព្រះអង្គﷺជាលើកទីពីរថាពួកគេនឹងគោរពព្រះអង្គﷺឥតប្រកែកឡើយ។ ភ្នែកពួកគេឆ្លុះបញ្ចាំងនូវឆន្ទៈពួកគេ ចំណែកឯចិត្តពួកគេឆ្លុះបញ្ចាំងនូវសេចក្ដីស្មោះត្រង់។

លុះភាគីគូរ៉យ៉ស្ញបានដឹងអំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅឯហ៊ុដៃ្ធប៊ីយ៉ាស់ហើយ ក៏បានចាត់បញ្ជូនអ្នកតំណាងម្នាក់ដែលមានឈ្មោះថា ស៊ូហៃ្ហល៍ ប៊ិន អុំរូ(سهيل بن عمرو) មកពិភាក្សារកវិធីកែខៃស្ថានភាពដុនដាប និងធ្វើកិច្ចព្រមព្រៀងសន្តិភាពជាមួភាគីមុស្លីម។ ក្រោយពីបានចរចាគ្នាយ៉ាងយូរ គេបានព្រមព្រៀងគ្នាផ្អាកវាយប្រហារគ្នាដោយមានលក្ខណ្ឌប្រាំខ ហើយប្រតិភូភាគីគូរ៉យ៉ស្ញនិងព្រះសាស្ដាក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

យោលតាមកិច្ចព្រមព្រៀងហ៊ុដៃ្ធប៊ីយ៉ាស់ ភាគីមុស្លីមត្រូវលះបង់ការបំពេញពិធីធម្មយាត្រា(ហាច្ឈ៍)ឆ្នាំនោះ ត្រូវត្រឡប់មកវិញឆ្នាំក្រោយដើម្បីបំពេញគ្រប់ពិធីដោយសេរីនិងតាមបែបបទដែលខ្លួនប្រាថ្នាចង់បំពេញនោះ។

ផ្ទុយពីអាការៈក្រៅ ព្រះសាស្ដាﷺនិងបណ្ដាសាវកភក្ដីបំផុតរបស់ព្រះអង្គﷺបានជ្រាបច្បាស់ថាយុទ្ធសន្តិភាពនេះជាជោគជ័យច្បាស់ទែងមួយ ព្រោះវាអាចជួយផ្សព្វផ្សាយសាសនាអ៊ីស្លាមពេញឧបទ្វីបអារ៉ាប់ដោយឥតទទួលរងការបង្ខិតបង្ខំ។

អល់ឡោះហ្ញ៍ﷻបានគាំទ្រទស្សនៈនេះ ដោយបានដាក់ចុះមកនូវស៊ូរ៉ោះត៊្គូរអានមួយដែលស្ដីអំពីរឿងនេះ និងដោយបញ្ជាក់ថា កិច្ចព្រមព្រៀងហ៊ុដៃ្ធប៊ីយ៉ាស់ជាជ័យជំនះ(فتح)យ៉ាងពិតប្រាកដ។ ទោះជាមានអាយ៉ាត់គូរអានអះអាងបញ្ជាក់ក្នុងរឿងនេះក៏ដោយ សាវកមួយចំនួនរបស់ព្រះសាស្ដាﷺបានយល់ឃើញថាខ្លួមានសិទ្ធិ

ជំទាស់ព្រះបញ្ញារបស់អល់ឡោះហ៊្ជ, និងរបស់ព្រះសាស្ដាﷺព្រះអង្គជ, តាមក្បាលចិត្តខ្លួនឯង ដោយបដិសេធកិច្ចព្រមព្រៀងហ៊ូដៃប៊ីយ៉ាស់នោះ។ មុស្លីមម្នាក់ ក្នុងចំណោមមុស្លីមទាំងនោះ បាននិយាយប្រឆាំងព្រះគម្ពីរគួរអានដោយគ្មានការប្រុងប្រយ័ត្នឡើយ ពេលគាត់បានឮគេសូត្រអាយ៉ាស់នេះ "*ពិតណាស់ យើងបានឲ្យអ្នកមានជ័យជំនះមួយដ៏ត្រចះត្រចង់*" (ស៊ូ.៤៨, អា.១) គាត់បានថា៖ "សូមស្បថលើអល់ឡោះហ៊្ជ! មិនមែនជ័យជំនះទេ!"

ម្ចាស់ប្រតិកម្មនេះគឺអ៊ុម៉ារ អ៊ិបនូ អាល់-ខ៉ត់ត្វប់ ដែលបានបង្កឲ្យមាននូវព្រឹត្តការណ៍មុនគេមួយដ៏ធ្ងន់ធ្ងរក្នុងប្រវត្តិសាស្ត្រអ៊ីស្លាមគឺ៖ ដោយធ្វើតាមតែក្បាលចិត្តឯង គាត់ហ៊ានប្រឆាំងព្រះបញ្ញារបស់អល់ឡោះហ៊្ជ,និងរបស់ព្រះសាស្ដាﷺព្រះអង្គជ,...

ប្រហែលជាមិនមែនជាការចៃដន់ទេ ដែលម្ចាស់កិរិយាដំបូងដ៏សម្បើមនេះបានរត់ចោលលានប្រយុទ្ធនៃសមរភូមិអ៊ូហ៊ូដ្ធយ៉ាងរលះរលាំងនោះ ចោលព្រះសាស្ដាﷺឲ្យនៅប្រយុទ្ធជាមួយបណ្ដាសាសនិកភ័ក្ដីមួយចំនួនតូច។

## ៦-សមរភូមិខុយ៉បារ

នាដើមខែរ៉ប់ប៊ីអ៊ុ អាល់-អាវ៉ាល់ ឆ្នាំទី ៧ សករាជហ៊ីច្ចរ៉ោះត៍ ព្រះសាស្ដាﷺបានសម្រេចព្រះហឫទ័យ វាយយកទឹកដីរបស់ពួកយ៉ាហ៊ូឌីនៃតំបន់អារ៉ាប់ដែល រហូតមកដល់ពេលនេះ នៅតែមានគម្រោងការអាក្រក់មកលើព្រះសាសនារបស់អល់ឡោះហ៊្ជ, ក្រោយពីត្រូវបណ្ដេញចេញពីម៉ាឌីណាស់ដោយសារតែពួកគេបានក្បត់ជាបន្តបន្ទាប់ហើយនោះ។

កន្លែងបណ្ដាកុលសម្ព័ន្ធយ៉ាហ៊ូឌីប្រជុំគ្នាហៅថាខុយ៉បារ ដែលមានកំពែងនិងបន្ទាយយ៉ាងច្រើន គ្រប់គ្រងលើផ្ទៃដីដ៏ច្រើនដែលមានជីវជាតិ។ ផ្ទៃដីមួយ ក្នុងចំណោមផ្ទៃដីដ៏មានជីវជាតិនោះ មានឈ្មោះថាផ្ទៃដីហ្វាដាក់។

ព្រះសាស្ដាﷺបានឆ្ពោះទៅកាន់ខុយ៉បារ ដោយមិនឲ្យអ្នកណាដឹងឡើយ ជាមួយរេហ៍ពលចំនួនមួយពាន់ប្រាំមួយរយនាក់។ ដើម្បីផ្ដាច់ជំនួយដែលអាចមកពីសម្ព័ន្ធមិត្តពហុទេពនិយមអារ៉ាប់របស់ពួកគេ បានូ ក៏ត្វហ្វាន់ (بنو غطفان) ព្រះអង្គﷺបានឆ្ពោះទៅកាន់តំបន់អាល់-រ៉យ៉ិអ៊ុ(الرجيع) ដែលនៅចន្លោះដែនដីសម្ព័ន្ធមិត្តទាំងពីរនេះ។

ពីទីតាំងនេះ ក្នុងពេលយប់។ ព្រះសាស្ដាﷺបានឡោមព័ទ្ធបន្ទាយខុយ៉បារ។ យុទ្ធជនអ៊ីស្លាមបានពួននៅក្នុងចម្ការលម៉ើដែលព័ទ្ធជុំវិញទីនោះ។

ព្រឹកឡើង ការប្រយុទ្ធបានចាប់ផ្ដើម កំពែងបានធ្លាក់ម្ដងមួយៗក្នុងដៃភាគីមុស្លីម។ តែមិនអាចវាយយកបន្ទាយក្រោយគេបានទេ។ យុទ្ធជនយ៉ាហ៊ូឌីបានប្រមូលផ្ដុំគ្នានៅទីនេះ ហើយបានប្រើគ្រាប់ព្រួញជាមធ្យោបាយរារាំងភាគីមុស្លីម។

ថ្ងៃដំបូងក្នុងការឡោមព័ទ្ធបន្ទាយនេះ ព្រះសាស្ដាﷺបានចាត់បញ្ជូនអាប៊ូ បាក់រ៍ (ឬ អាប៊ូ បាការ) ជាមេដឹកនាំទ័ពមួយ ទៅវាយយកបន្ទាយនោះ តែត្រូវបរាជ័យ។

ថ្ងៃទីពីរ ព្រះអង្គﷺបានចាត់បញ្ជូនអ៊ុម៉ារទៅតែបានទទួលបរាជ័យក្នុងការវាយបំបែកខ្សែត្រៀមការពារបន្ទាយ។

បរាជ័យពីរដងនេះបានធ្វើឲ្យភាគីយ៉ាហ៊ូឌីមានកម្លាំងចិត្តឡើង ហើយបាននិយាយចំអកឲ្យយុទ្ធជន

អ៊ីស្លាម។

ព្រះសាស្ដាصلى الله عليه وآله وسلمមានព្រះវចនៈថា៖ "ពិតណាស់ ថ្ងៃស្អែកខ្ញុំនឹងផ្ទេរបញ្ជាការឲ្យទៅបុរសម្នាក់ដែលស្រឡាញ់អល់ឡោះហ៊្ញ عز وجل និងព្រះសាស្ដាصلى الله عليه وآله وسلمព្រះអង្គعز وجل ហើយដែលអល់ឡោះហ៊្ញعز وجلនិងព្រះសាស្ដាصلى الله عليه وآله وسلمព្រះអង្គعز وجل ស្រឡាញ់។ គេអង់អាច វាយសម្រុកឥតរួញរា មិនរត់ចោលលានប្រយុទ្ធទេ។ ដរាបណាអល់ឡោះហ៊្ញعز وجلមិនប្រទានជ័យជំនះឲ្យគេទេ ដរាបនោះគេមិនប្រឡប់ក្រោយទេ។"

យប់នោះ ភាគីមុស្លីមបានដណ្ដឹងសួរខ្លួនឯងថាបុរសមានសំណាងនោះជាអ្នកណាទៅ។ ម្នាក់ៗស្រមៃឃើញថាខ្លួនឯងជាបុរសជោគជ័យរូបនោះ។

ព្រឹកនៃថ្ងៃទីបី ព្រះសាស្ដាصلى الله عليه وآله وسلمបានហៅអ៊ុាលីصلوات الله عليه والسلامមកជួប។ ព្រះអង្គصلى الله عليه وآله وسلمបានប្រគល់ទង់ឲ្យអ៊ុាលីصلوات الله عليه والسلام ហើយបានបួងសួងអល់ឡោះហ៊្ញعز وجلសូមឲ្យព្រះអង្គعز وجلជួយឲ្យអ៊ុាលីصلوات الله عليه والسلامបានទទួលជ័យជំនះយ៉ាងងាយស្រួល។



អាលីصلوات الله عليه والسلامបានសម្រុកចូលយ៉ាងអង់អាច ជាមួយរបៅពលព្រះអង្គصلوات الله عليه والسلام ទៅវាយដណ្តើមយកបន្ទាយអបរាជ័យ។

ជ័យជំនះថ្ងៃមុនបានលើកកម្លាំងចិត្តយុទ្ធជនយ៉ាហ៊ូឌី។ អាស្រ័យហេតុនេះ ពួកគេហ៊ានចេញមកខាងក្រៅកំពែង។ ការប្រយុទ្ធដ៏សម្បើមក៏បានចាប់ផ្តើមឡើងពេលទ័ពរបស់អាលីصلوات الله عليه والسلامបានមកដល់។ មិនយូរប៉ុន្មានអាលីصلوات الله عليه والسلامបានសម្លាប់មេទ័ពយ៉ាហ៊ូឌីដ៏ល្បីល្បាញពីរនាក់ដែលមានឈ្មោះថា ម៉ារហ្ហាប់ និង អាល់-ហ្ហារីស្ហ ដែលល្បីថាមិនដែលចាញ់គេឡើយក្នុងការប្រយុទ្ធតតួ។

យុទ្ធជនយ៉ាហ៊ូឌីងទៀតភ័យរន្ធត់ ប្រញាប់ត្រឡប់ទៅកាន់បន្ទាយវិញហើយពង្រឹងទ្វារបន្ទាយឲ្យកាន់តែមាំឡើង។ ភាគីមុស្លីមបានមកទាល់នៅត្រង់មុខទ្វារនេះ គ្មានសមត្ថភាពចូលទៅបានទេ។

កាលនោះអាលីصلوات الله عليه والسلامបានចាប់កងលើទ្វារនោះអង្រួនយ៉ាងខ្លាំង ហើយបានកន្ត្រាក់ទ្វារនោះមកធ្វើជាស្ពានឲ្យទ័ពភាគីមុស្លីមឆ្លងចូលទៅខាងក្នុងបន្ទាយ។ ភាគីយ៉ាហ៊ូឌី ដែលភ័យរន្ធត់ បានចុះចាញ់ ដោយសារតែបានឃើញផ្ទាល់ភ្នែកនូវកម្លាំងពលំរបស់អាលីصلوات الله عليه والسلام។

ភាគីមុស្លីមក៏រន្ធត់មិនចាញ់ភាគីយ៉ាហ៊ូឌីទេដែរ ពួកគេដណ្តឹងសួរខ្លួនឯងថាតើអាស្រ័យហេតុអស្ចារ្យអ្វីទៅបានជាអាលីصلوات الله عليه والسلامអាចអង្រួនហើយកន្ត្រាក់ទ្វារបន្ទាយបាន ទ្វារដែលយុទ្ធជនមុស្លីមខ្លាំងជាងគេប្រាំពីរនាក់មិនទាំងអាចធ្វើឲ្យរង្គើបានផងនោះ? អាលីصلوات الله عليه والسلامបានប្រាប់ពួកគេថា៖ ខ្ញុំصلوات الله عليه والسلامមិនបានធ្វើដូចនេះអាស្រ័យកម្លាំងបាយនោះទេ តែអាស្រ័យព្រះថាមពល។

ភាគីយ៉ាហ៊ូឌីបានសូមធ្វើកិច្ចសន្យាសន្តិភាព និងសូមឲ្យព្រះសាស្តាﷺអនុញ្ញាតឲ្យពួកគេរស់នៅក្នុងលំនៅដ្ឋានពួកគេ ដោយព្រមប្រគល់ផលដំណាំពាក់កណ្តាលរបស់ពួកគេឲ្យទៅភាគីមុស្លីម។ ព្រះសាស្តាﷺ បានយល់ព្រមហើយបានលើកលែងទោសឲ្យពួកគេ។

## ហ្វាដាក់(فدك)

លុះដំណឹងជ័យជំនះរបស់ភាគីមុស្លីមបានលេចឮ ដល់ភាគីយ៉ាហ៊ូឌីនៃតំបន់ហ្វាដាក់ ពួកគេប្រញាប់សូមធ្វើកិច្ចសន្យាសន្តិភាពជាមួយភាគីមុស្លីម ហើយបានសូមប្រគល់ឲ្យទៅព្រះសាស្តាﷺ នូវដីដែលពួកគេធ្វើកសិកម្មនោះចំនួនពាក់កណ្តាល ដូរនឹងការលើកលែងទោសពីព្រះអង្គﷺ។ ព្រះសាស្តាﷺបានយល់ព្រមហើយបានយកពាក់កណ្តាលនៃដីហ្វាដាក់មកជាកម្មសិទ្ធិរបស់ព្រះអង្គﷺ។ បន្ទាប់មកព្រះអង្គﷺបានប្រគល់ដីទាំងនេះឲ្យទៅព្រះរាជបុត្រីតែមួយរបស់ព្រះអង្គﷺ ហ្វាទីម៉ាស់سلام الله عليها ដែលជាព្រះរាជអគ្គមហេសីរបស់អាលីصلوات الله عليه والسلام សាវកភ័ក្តីរបស់ព្រះអង្គﷺផងដែរ។

ការពិត គេអាចយល់បានអំពីការប្រគល់ដីនេះដោយផ្អែកទៅលើតួនាទីរបស់ព្រះរាជបុត្រីسلام الله عليهاរបស់ព្រះសាស្តាﷺ និងតួនាទីរបស់ព្រះស្វាមីصلوات الله عليه والسلامព្រះនាង។ សម្រាប់ព្រះអង្គទាំងពីរعليهم السلام ដីហ្វាដាក់ដ៏មានជីវជាតិជាប្រទភពនៃការនាំមកនូវថវិកាគ្រប់គ្រាន់ដើម្បីបន្តកិច្ចសប្បុរសធម៌ និងដើម្បីចាយវាយទៅលើផលប្រយោជន៍ក្នុងការផ្សព្វផ្សាយព្រះឱង្ការអល់ឡោះហ៍عزّ وجلّ។

ព្រះសាស្តាﷺបានឆ្ពោះទៅកាន់ទីតាំងចុងក្រោយបង្អស់ របស់ភាគីយ៉ាហ៊ូឌីនៅក្នុងឧបទ្វីបអារ៉ាប់ គឺជ្រលងអាល់-គូរ៉(القرى)ដែលបានធ្លាក់មកក្នុងកណ្តាប់ដៃភាគីមុស្លីមភ្លាមៗ។

ព្រះសាស្តាﷺបានលើកលែងទោសឲ្យភាគីយ៉ាហ៊ូឌី ដោយឲ្យពួកគេប្រគល់ប្រាក់ចំណូលពាក់កណ្តាលរបស់ពួកគេមកឲ្យភាគីមុស្លីម។

ជ័យជំនះ និងទង្វើទាំងនេះបានធ្វើឲ្យគោលជំហររបស់ភាគីមុស្លីមកាន់តែមាំមួនឡើង ទាំងវិស័យថវិកានិងវិស័យយោធា។ អាស្រ័យលើលក្ខខណ្ឌទាំងនេះ ព្រះសាស្តាﷺបានចាត់បញ្ជូនប្រេសិតទៅរកក្សត្រជិតខាងទាំងឡាយនាសម័យនោះ ស្នើឲ្យពួកគេចូលសាសនាអ៊ីស្លាម។ គេបានទទួលស្វាគមន៍ប្រេសិតមួយចំនួន ឯមួយចំនួនទៀត ជួនកាល ត្រូវគេសម្លាប់។

## ៧-សមរភូមិមុតាស់(مؤتة)

អភិបាលក្រុងប៊ុស្វ៉ារ(بصرى ទីក្រុងសព្វថ្ងៃរបស់ប្រទេស Jordanie) ហ៊ានសម្លាប់ប្រេសិតម្នាក់របស់ព្រះសាស្តាﷺ។ មិនអាចអត់ឱនបទឧក្រិដ្ឋនេះបានឡើយ ព្រះសាស្តាﷺបានបញ្ជាឲ្យចេញទៅធ្វើទណ្ឌកម្មបុគ្គលប្រមាថសាសនារូបនេះ។

គេបានកែនពលមុស្លីមមួយដែលមានយុទ្ធជនចំនួនបីពាន់នាក់។ ព្រះសាស្តាﷺបានតែងតាំងជាមេដឹកនាំយ៉ាក់ហ្វារ ប៊ិន អាប៊ូ ត៉ូលិប បងប្អូនជីដូនមួយរបស់ព្រះអង្គﷺ ដែលជាសាវកភ័ក្តីរបស់ព្រះអង្គﷺ ដោយមានសៃដ៍ ប៊ិន ហារីស្វាស់ ជាមេដឹកនាំរង និងដោយមានអាប់ឌុលឡោះហ៍ ប៊ិន រ៉ាហ៊ិះត៍ បុរសអាន់ស្វ៉ារី ជាមេដឹកនាំបន្ទាប់ពីសៃដ៍ ប៊ិន ហារីស្វាស់។

លុះទ័ពមុស្លីមបានមកដល់មុតាស់ ពួកគេភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលបានឃើញទ័ពសត្រូវមានចំនួនច្រើន។ គួរឲ្យជឿថាពួកសត្រូវប្រាកដជាបានដឹងជាមុនអំពីយុទ្ធការ ហើយបានត្រៀមទ័ពជាស្រេចដែលមានរេហ៍ពលចំនួនពីររយពាន់នាក់ប្រដាប់ដោយឧបករណ៍យោធាទំនើបនៃសម័យនោះ។

ការពិត អភិបាលក្រុងប៊ុស្វ៉ារជាបម្រើរបស់ចក្រភពរ៉ូម។ ដូច្នេះហើយបានជាលោកមាននូវមធ្យោបាយគ្រប់បែបរបស់ចក្រភពដ៏សម្បើមនេះ។

ទោះជាមានកម្លាំងមិនស្មើគ្នាក៏ដោយ ភាគីមុស្លីមបានតស៊ូយ៉ាងអង់អាច ដោយការតស៊ូដែលជិតជាប់នៅក្នុងប្រវត្តិសាស្ត្រ។ មេបញ្ជាការទាំងបីរូបរបស់ពួកគេបានលះបង់ជីវិតជាបន្តបន្ទាប់គ្នាក្នុងសមរភូមិនេះ... នៅក្នុងខណៈដ៏សំខាន់នេះ ភាគីមុស្លីមបានជ្រើសរើសខ៉ំលិដ្ អ៊ីបនូ អាល់-វ៉ាលីដ្(خالد بن الوليد) ដែលទើបនឹងបានចូលសាសនាអ៊ីស្លាមថ្មីៗ ជាមេបញ្ជាការ។ ខ៉ំលិដ្ អ៊ីបនូ អាល់-វ៉ាលីដ្បានសម្រេចចិត្តដកថយក្នុងពេលយប់។

ដូច្នេះឯងដែលទ័ពមុស្លីមដែលនៅសេសសល់ អាចត្រឡប់មកកាន់ម៉ាឌីណាស់វិញបាន បន្ទាប់ពីបានចារទុកនូវវីរៈប្រវត្តិលះបង់ជីវិតដើម្បីអល់ឡោះហ៍عز وجلមួយទំព័រក្នុងប្រវត្តិសាស្ត្រ។

## ៨-ភាគីគូរ៉យស្ស៍ក្បត់កិច្ចសន្យាហ៊ូដៃប៊ីយ៉ាស់

ដំណឹងសមរភូមិមុតាស់បានលេចឮមកដល់ពួកគូរ៉យ៉ស្ង ដែលបានយល់ឃើញថាបរាជ័យនេះជាប្រផ្នូលឲ្យដឹងមុនថា នឹងមានបរាជ័យច្រើនទៀតនៅពេលខាងមុខ។ ពួកគេហ៊ានគិតជាមុនថាសាសនាអ៊ីស្លាមចាប់ផ្តើមរលត់រលាយអសាបង់ជាស្ថាពរហើយ...

ការប្រញាប់សន្និដ្ឋាន និងការសន្មតខុសរបស់ពួកគេនេះបានជម្រុញភាគីគូរ៉យ៉ស្ងឲ្យប្រហារជីវភាពរស់នៅរបស់ខ្លួនឯង ក្នុងឋានៈជាអ្នកគោរពបូជារូបបដិមា ដោយដៃឯង។ ពិតណាស់ ជនប្រមាថសាសនាទាំងនេះបានវាតត្បាតយ៉ាងកំរោលទៅលើសម្ព័ន្ធមិត្តរបស់ភាគីមុស្លីម ដែលនៅជិតម៉ាក់កាស់ណាស់ គឺកុលសម្ព័ន្ធបានូខូស្សាអ៊ាស់(بنو خزاعة)។

ជនរងគ្រោះទាំងនេះបានសូមជំនួយពីសម្ព័ន្ធមិត្តរបស់ខ្លួន នៃនគរម៉ាឌីណាស់។ ព្រះសាស្តាﷺបានសម្រេចព្រះហឫទ័យបង្ហើយឲ្យចប់ជាស្ថាពរតែម្តងជាមួយពួកឥតសាសនានៃនគរម៉ាក់កាស់ទាំងនេះ។

នៅក្នុងចន្លោះពេលនេះ អាប៊ូ ស៊ុហ្វយ៉ានបានយល់ច្បាស់ថាភាគីគូរ៉យ៉ស្ងបានយល់ខុសយ៉ាងធ្ងន់ ហើយ



ប្រញាប់ប្រញាល់ឆ្ពោះទៅកាន់ម៉ាឌីណាស់ដើម្បីសូមធ្វើកិច្ចព្រមព្រៀងសន្តិភាពសាថ្មី និងសូមពន្យារសន្តិភាព។ តែព្រះសាស្ដាﷺបានបដិសេធ ព្រះអង្គﷺមិនព្រមទទួលអាប៊ូ សុិហ្វយ៉ានទេ។ មុស្លីមទាំងអស់នៃនគរម៉ាឌីណាស់មិននិយាយរកលោកទេ។

សូម្បីតែកូនស្រីរបស់លោកឈ្មោះ អ៊ូម ហាប៊ីបាស់(أم حبيبة) ដែលជារាជមហេសីមួយរូបរបស់ព្រះសាស្ដាﷺ ក៏មិនយកចិត្តទុកដាក់ទេដែរក្នុងការទទួលស្វាគមន៍ឪពុកតាមធម្មតាដែលមកលេងនោះ...

ទីបំផុត អាប៊ូ សុិហ្វយ៉ានបានត្រឡប់មករកភាគីគូរ៉យស៍វិញដៃទទេ។ ពួកគោរពបូជារូបបដិមានៃនគរម៉ាក់កាស់ព្រួយបារម្ភអនេក។

# ៣. ក្រោយជ័យជំនះ

## ការវាយដណ្តើមយកនគរម៉ាក់កាស់

ព្រះសាស្តាﷺបានបញ្ជាឲ្យភាគីមុស្លីមត្រៀមខ្លួនប្រយុទ្ធ។ ព្រះអង្គﷺបានកែនទ័ពមួយដែលមានវេហ៍ពលដប់ពាន់នាក់ ព្រមទាំងលាក់ការសម្ងាត់ មិនឲ្យលេចឮឡើយ។ ដើម្បីទប់ស្កាត់ការលេចឮដំណឹងទៅដល់ភាគីគូរ៉យស្ ព្រះសាស្តាﷺបានដាក់ទ័ពយាមល្បាតនៅជុំវិញបុរី។



មុស្លីមម្នាក់ ព្រោះតែចង់បានមិត្តភាពពីពួកគូរ៉យ៉ស្ង់ បានចាត់បញ្ជូននារីម្នាក់ទៅរកពួគេជាមួយព័ត៌មានសម្ងាត់។ តែអល់ឡោះហ៍្វ عز وجل បានប្រាប់ឲ្យព្រះសាស្តាﷺជ្រាបអំពើក្បត់នេះ។ អ៊ុាលីصلوات الله عليه والسلامបានស្ទាក់ផ្លូវនារីនោះ ហើយបានយកព័ត៌មានសម្ងាត់មកវិញ។

បុរសក្បត់ ដែលមានឈ្មោះថាហ្ញាត្ទិប ត្រូវគេចាប់ខ្លួនបានហើយបានសារភាពបទឧក្រិដ្ឋ។ គាត់បានអះអាងថា គាត់ជឿជាក់ថាភាគីមុស្លីមច្បាស់នឹងឈ្នះ ធ្វើឲ្យគាត់អត់ទ្រាំចងមិត្តភាពជាមួយពួកគូរ៉យ៉ស្ង់មិនបាន ដោយគិតថាវានឹងមិនធ្វើឲ្យស្ថានភាពភាគីមុស្លីមអាចដុនដាបបាននោះទេ។

ព្រឹត្តិការណ៍នេះសឲ្យដឹងថា មានអារម្មណ៍ទន់ខ្សោយក្នុងចំណោមមុស្លីមនៃនគរម៉ាឌីណាស្ងំ។ ហើយមិនយូរប៉ុន្មានស្ថានភាពនេះនឹងលេចឡើងយ៉ាងច្បាស់ទែងលើសនេះទៅទៀត ដោយជះឥទ្ធិពលអាក្រក់ទៅលើវិវឌ្ឍន៍នយោបាយ អត់ពីព្រះសាស្តាទៅ។

ថ្ងៃទី ១០ ខែរ៉ម៉ាដ្ធន ទ័ពមុស្លីមបានឆ្ពោះទៅកាន់នគរម៉ាក់កាស្ង់។ លុះមកដល់បរិវេណបុរីពិសិដ្ឋ ព្រះសាស្តាﷺអល់ឡោះហ៍្វ عز وجل ព្យាយាមចៀសវាងការប្រយុទ្ធបង្ហូរឈាមដោយប្រើវិធីចិត្តសាស្ត្រ ដើម្បីកម្ចាត់ការប៉ុនប៉ងក្បត់ពីសំណាក់ពួកពហុទេពិយមនៃនគរម៉ាក់កាស្ង់។

ដូច្នេះ ពេលយប់ ព្រះសាស្តាﷺបានបញ្ជាឲ្យយុទ្ធជនទាំងអស់ដុតភ្លើងបំភ្លឺ។ ទិដ្ឋភាពគគ្រឹកគគ្រេងអនេក។ អាប៊ូ ស៊ុហ្វយ៉ាន ដែលឃ្លាំមើលទិដ្ឋភាពនេះពីចម្ងាយ ភ័យរន្ធត់ហើយបានសន្និដ្ឋានយ៉ាងរហ័សថាពួកអ្នកស្រុកម៉ាក់កាស្ង់មិនអាចទប់ទល់ពួកមុស្លីមបានឡើយ ដែលមានគ្នាច្រើននិងប្តេជ្ញាចិត្តនោះ។

អាប៊ូ ស៊ុហ្វយ៉ាន បានទៅសូមឲ្យអ៊ុាប់បាស់ ឪពុកមារបស់ព្រះសាស្តាﷺ ដែលរស់នៅឯនគរម៉ាក់កាស្ង់នោះ ជួយធ្វើអន្តរាគមន៍។

ការចចារជាមួយព្រះសាស្តាﷺអល់ឡោះហ៍្វ عز وجل បានសម្រេចឲ្យភាគីគូរ៉យ៉ស្ង់ចុះចាញ់ ប្តូរនឹងការលើកលែងទោសជាទូទៅ។

## ការលើកលែងទោសទូទៅ

បណ្តាមុស្លីមអ្នកច្បាំងឈ្នះមួយចំនួនធំពាំទុកនូវគំនុំសងសឹក ដោយសារតែបានទទួលរងនូវទុក្ខវេទនាពីសំណាក់គូរ៉យ៉ស្ង់។ តែព្រះសាស្តាﷺបានសម្រេចព្រះហឫទ័យយ៉ាងម៉ឺងម៉ាត់ហើយគឺៈ សូម្បីតែបុគ្គលដែលបានប្រព្រឹត្តអាក្រក់មកលើរូបព្រះសាស្តាﷺផ្ទាល់ក៏ត្រូវលើកលែងទោសឲ្យដែរ។

បញ្ជាចម្បងរបស់ព្រះសាស្តាﷺគឺបោសសម្អាតកាក់បស្ង់ ឲ្យអស់រូបបដិមាដែលមានពាសពេញនៅក្នុងនោះ។ អ៊ុាលីصلوات الله عليه والسلامជាអ្នកបំពេញបេសកកម្មដែលងាយទៅជាបញ្ជា ដែលតម្រូវឲ្យវាយកម្ទេចរូបបដិមានៅចំពោះមុខពួកអ្នកស្រុកម៉ាក់កាស្ង់ដែលយំសស្រាក់។

សេចក្តីក្លាហាននិងភ័ក្តីភាពឥតលក្ខខណ្ឌរបស់បុរសដ៏វិសេសវិសាលរូបនេះ នឹងនាំមកលើរូបព្រះអង្គ

صلوات الله عليه والسلامនូវគន្ធនុំគុំកួនដែលមិនចេះអស់ពីសំណាក់អ្នកស្រុកម៉ាក់កាស់ដែលទើបនឹងស្គាល់លទ្ធិអ៊ីស្លាម។

បន្ទាប់មកប៊ីឡាល់បានឡើងទៅលើដំបូលកាក់បាស់ សូត្របង្លូកឲ្យបំពេញនមស្ការ(អាស៊ាន أذان)ជាគ្រាដំបូងបង្អស់។

## សមរភូមិហ៊ូណៃន៍(حنين)

ការវាយដណ្ដើមយកម៉ាក់កាស់បានដោយភាគីមុស្លីម បានធ្វើឲ្យកុលសម្ព័ន្ធអារ៉ាប់ធំៗជ្រួលច្របល់និងព្រួយបារម្ភ។ ពួកគេមានបំណងយកឈ្នះភាគីមុស្លីមនៅក្នុងដែនអំណាចពួកគេនោះតែម្តង។

ដូច្នេះ កុលសម្ព័ន្ធហាវ៉ាស៊ាន(هوازن) និងកុលសម្ព័ន្ធស្ហាគិហ្វបានកែនទ័ពធំមួយដែលមានវរហ៍ពល ១២០០០ នាក់ហើយបានប្រគល់បញ្ជាការឲ្យទៅម៉ាលិក ប៊ិន អោហ្វ(مالك بن عوف) បុរសអារ៉ាប់ដែលមានឈ្មោះល្បីល្បាញ។

ដោយដឹងថាព្រះសាស្ដាﷺនិងទ័ពព្រះអង្គﷺ មានបំណងចេញមកប្រឈមពួកគេ ពួកគេបានយកទីតាំងនៅលើភ្នំហ៊ូណៃន៍ ចាំមើលទ័ពមុស្លីមកាត់មកតាមជ្រលងដែលអាចគ្រប់គ្រងបានយ៉ាងងាយ។

ទ័ពមុស្លីមដំបូងបង្អស់ ត្រួតត្រាដោយខ៉ូលិដ្ អ៊ិបនូ អាល់-វ៉ាលិដ្ បានមកដល់បណ្ដាលជ្រលងនៅពេលមុនថ្ងៃរះ។

ពួកគេត្រូវពួកសត្រូវលួចវាយឆ្មក់ ដោយបាញ់គ្រាប់ព្រួញស្រោចមកលើ។ កងពលមុស្លីមបានដកថយដោយឥតសណ្ដាប់ធ្នាប់ បណ្ដាលឲ្យមានភាពឥតសណ្ដាប់ធ្នាប់និងភាពចលាចលនៅក្នុងទ័ពមុស្លីម។ ស្ថានភាពកាន់តែដុលដាបពេលពួកប្រមាថសាសនាបានចេញមកពីកន្លែងពួន ហើយបានវាយប្រហារភាគីមុស្លីមស្លាប់អស់ច្រើន។

មុស្លីមភាគច្រើនគិតថាត្រូវបរាជ័យហើយ ក៏បានចាប់ផ្ដើមរត់ចោលលានប្រយុទ្ធ។

ខណៈដែលកំពុងជួបប្រទះមហន្តរាយ បណ្ដាអ្នកមានសទ្ធាភ័ក្តិមួយចំនួនតូច ក្រោមការដឹកនាំរបស់អាលី صلوات الله عليه والسلام បានតស៊ូនិងបានប្រយុទ្ធយ៉ាងសាហាវ។ ចំណែកឯព្រះសាស្ដាﷺបង្លូកហៅបណ្ដាអ្នកមានសទ្ធាឲ្យតស៊ូតទល់ ហើយបានសូមឲ្យអ៊ាប់បាស់ ឪពុកមាព្រះអង្គﷺដែលមានសម្លេងល្បឺ ប្រកាសហៅពួករត់គេចត្រឡប់មកវិញនិងរំលឹកពួកគេ សូមឲ្យគោរពតាមពាក្យសន្យាដែលពួកគេបានធ្វើចំពោះអល់ឡោះហ៍ﷻនិងចំពោះព្រះសាស្ដាﷺព្រះអង្គﷻនោះ។

បន្តិចម្តងៗ ភាគីមុស្លីមភ្ញាក់ស្មារតីឡើងវិញហើយត្រឡប់មកទីតាំងខ្លួនវិញ មករកការកោះហៅរបស់ព្រះសាស្ដាﷺដែលបានបង្លូកខ្លាំងៗថា៖ "ខ្ញុំﷺគឺព្រះសាស្ដាﷺ ចូរមករកខ្ញុំﷺ។"

ការប្រកាសហៅរបស់ព្រះសាស្ដាﷺ និងរបស់ឪពុកមាព្រះអង្គﷺបាននាំត្រឡប់មករកមេបញ្ជាការពួកគេវិញនូវយុទ្ធជនចំនួនពីររយនាក់។ នៅពេលប្រយុទ្ធផ្តាច់ព្រ័ត្រ អាលីصلوات الله عليه والسلامបានសម្លាប់ខ្មាន់ទង់របស់ពួកពហុទេពនិយម។ លុះបានឃើញទង់ពហុទេពនិយមធ្លាក់ដី ពួកមុស្លីមបានត្រឡប់មកប្រយុទ្ធវិញ ចំណែកឯពួកប្រមាថសាសនាភ័យរន្ធត់ ហើយធ្លាក់ទឹកចិត្ត។

ពេលនោះ ព្រះសាស្ដាﷺបានបញ្ជាឲ្យសាសនិកភ័ក្តីរបស់ព្រះអង្គﷺវាយបកវិញយ៉ាងសម្បើមដោយមានព្រះវចនៈថា៖ "ពេលនេះហើយដែលត្រូវប្រយុទ្ធយ៉ាងសកម្មនោះ សម្រុកចូលទៅរកពួកគេទៅ!"

ជ័យជំនះយ៉ាងត្រចះត្រចង់បានមកលើភាគីមុស្លីម។

## សមរភូមិតាប៊ុក(تبوك)

ខែរ៉យ៉ាប់ ឆ្នាំទី ៩ សករាជហ៊ីជ្រ៉ោះត៍ ដំណឹងថាមានការប្រជុំទ័ពរ៉ូមយ៉ាងធំមួយនៅឯព្រំប្រទល់នៃទិសខាងជើងនៃទ្វីបអារ៉ាប់ សឲ្យឃើញថាមានការបម្រុងវាយប្រហារយ៉ាងធំមួយមកលើតំបន់ខាងជើង។

ព្រះសាស្តាﷺបានសម្រេចព្រះហឫទ័យធ្វើកិច្ចប្រតិបត្តិការបង្ការនិងទប់ស្កាត់យ៉ាងធំមួយ។ ផ្ទុយពីសព្វដង ព្រះអង្គﷺមិនប្រើវិធានសម្ងាត់ទេ ផ្ទុយទៅវិញ ព្រះអង្គﷺប្រកាសកែនទ័ព បញ្ជាឲ្យមុស្លីមគ្រប់រូបដែលមានសមត្ថភាពប្រយុទ្ធបាននោះ ត្រៀមខ្លួនចូលរួមក្នុងសមរភូមិធំតទល់ពួករ៉ូម។

មុស្លីមប្រុសស្រីបានសម្តែងនូវសេចក្តីអើពើ និងសេចក្តីក្លាហានដែលមិនធ្លាប់មានកាលពីមុនចំពោះការប្រកាសរបស់ព្រះសាស្តាﷺនេះ។ ពិតណាស់ ពួកគេបាននាំមកនូវសព្វសារពើដែលមានសារប្រយោជន៍សម្រាប់សមរភូមិ ដូចជាយានជំនិះនិងគ្រឿងអលង្ការជាដើម។

## ម៉ាស់យ៊ិដរបស់ពួកលាក់ពុតត្បុត

ទន្ទឹមនឹងព្រឹត្តិការណ៍នេះ ពួកលាក់ពុតត្បុតនៃនគរម៉ាឌីណាស៉ុខំទ្រាំយ៉ាងក្តៅក្រហាយ អន្ទះសាចង់ឃើញសាសនាអ៊ីស្លាមដួលរលំក្រោមការវាយប្រហាររបស់សំណាក់រ៉ូម។

ក្នុងពេលដែលបុព្វករណ៍យុទ្ធការកំពុងតែប្រព្រឹត្តទៅដល់ថ្នាក់កំពូល ពួកលាក់ពុតត្បុតបានសាងសង់ម៉ាស់យ៊ិដមួយ ហើយបានមកសូមឲ្យព្រះអង្គﷺធ្វើធម្មានុរូបកម្ម(សូមឲ្យសមរម្យត្រឹមត្រូវតាមច្បាប់)ម៉ាស់យ៊ិដនេះ ដោយសូមអញ្ជើញព្រះអង្គﷺមកធ្វើនមស្ការក្នុងម៉ាស់យ៊ិដនេះ។

ព្រះសាស្តាﷺ ទ្រង់ញាណគម្រោងការអប្រិយរបស់ពួកលាក់ពុតត្បុត។ ព្រះអង្គﷺបានចាត់បញ្ជូនមុស្លីមមួយក្រុមទៅលុបចាប់ពួកគេដែលកំពុងតែជួបជុំគ្នាក្នុងអង្គប្រជុំសម្ងាត់មួយ នៅឯផ្ទះរបស់បុគ្គលយ៉ាហ៊ូឌីម្នាក់ដែលមានឈ្មោះថា ស៊ូវ៉ៃឡាំ។

តែកាលនោះស្ថានភាពទូទៅមិនអាចតម្រូវឲ្យធ្វើសកម្មភាពធំដុំបានទេ គ្រាន់តែបានចុះដៃបង្ក្រាបមួយដងមួយកាលដែលធ្វើឲ្យពួកលាក់ពុតរត់បែកខ្ញែកគ្នា។

## ឆ្ពោះទៅកាន់តាប៊ុក

ការចេញដំណើរទៅកាន់តាប៊ុកបានចាប់ផ្តើម។ បន្ទាប់ពីបានកែនទ័ពយ៉ាងខ្នះខ្នែង ទ័ពមុស្លីមមានរេហ៍ពលដល់ទៅសាមសិបពាន់នាក់។ ទាំងអស់គ្នាបានចាប់ផ្តើមធ្វើដំណើរដ៏ឆ្ងាយ មានចម្ងាយផ្លូវប្រាំមួយរយគីឡូម៉ែត្រកណ្តាលវាលខ្សាច់ និងក្រោមកម្តៅថ្ងៃនៃរដូវក្តៅ។

ដោយសារតែពួកលាក់ពុតត្បុតជាតួអង្គសំខាន់នៃនគរម៉ាឌីណាស៉ុ ព្រះសាស្តាﷺពុំមានបុគ្គលណាផ្សេង

ពីអ៊ុាលីصلوات الله عليه والسلام សាវកភ័ក្តីរបស់ព្រះអង្គﷺទេជាអ្នកតំណាងព្រះអង្គﷺ និងជាអ្នកដោះកលឧបាយនិងគម្រោងការអាក្រក់របស់ពួកនេះ។ ជម្រើសនេះមានសារសំខាន់កំពូល ហើយបញ្ជាក់ប្រាប់យ៉ាងច្បាស់ចំពោះភាគីមុស្លីមថាអ៊ុាលីصلوات الله عليه والسلامមិនគ្រាន់តែជាវីរៈបុរសសង្គ្រាមប្រសើរលើសគេនោះទេ តែព្រះអង្គصلوات الله عليه والسلامជាមគ្គុទេសក៍ដឹកនាំនយោបាយឆ្នើមដែរបន្ទាប់ពីព្រះសាស្តាصلوات الله عليه والسلام។



ការពិត ព្រះសាស្តាﷺមានព្រះបំណងចង់ឲ្យបណ្តាមុស្លីមស្គាល់ឋានន្តរស័ក្តិរបស់អ៊ុាលីصلوات الله عليه والسلامសម្រាប់អល់ឡោះហ៍عز وجلនិងព្រះសាស្តាព្រះអង្គعز وجل។ ពេលពួកលាក់ពុតត្បុតបាននិយាយបង្កាច់បង្ខូចអ៊ុាលីصلوات الله عليه والسلام ដោយ

ព្យាយាមមើលងាយព្រះអង្គصلوات الله عليه والسلامដោយសារបេសកកម្មនេះ ព្រះសាស្តាﷺបានចាប់យកឱកាសនេះ ហើយមានព្រះវចនៈប្រាប់អ៊ាលីصلوات الله عليه والسلامក៏ដូចប្រកាសប្រាប់មុស្លីមដែរថា៖ "*ពួកគេបាននិយាយបង្កាច់! ខ្ញុំﷺគ្រាន់តែប្រគល់ឲ្យទៅអស់លោកនូវអ្វីដែលខ្ញុំﷺបានបន្សល់ទុកពេលអត់ពីខ្ញុំﷺទៅនោះទេ! អ្នកصلوات الله عليه والسلامមិនចង់នៅក្បែរខ្ញុំﷺដូចហារូនعليه السلامនៅក្បែរមូសាعليه السلامទេឬ? តែអត់ពីខ្ញុំﷺទៅមិនមានព្រះសាស្តាទៀតទេ ។*"

ទ័ពមុស្លីមបានមកដល់តាប៊ុក។ ដំណឹងបានលេចឮទៅដល់ភាគីរ៉ូម តែភាគីរ៉ូមមិនចូលលានប្រយុទ្ធទេ ព្រោះមិនជឿជាក់ថាប្រាកដនឹងឈ្នះភាគីមុស្លីមនោះទេ។ ភាគីរ៉ូមក៏បានដកថយ ទុកឲ្យភាគីមុស្លីមជ្រើសរើសយកការប្រយុទ្ធឬគ្រាន់តែទទួលបាននូវជ័យជំនះខាងផ្លូវចិត្តប៉ុណ្ណោះ។

ព្រះសាស្តាﷺសុខចិត្តមិនបង្កសង្គ្រាម ហើយបានបញ្ជាឲ្យកនព្រះអង្គﷺបោះជំរំនៅកណ្តាលវាល ដើម្បីបង្ហាញកម្លាំងទ័ពនិងអាជ្ញា និងសម្តែងអាការគោរពបូជាដ៏ជ្រះថ្លាចំពោះអល់ឡោះហ៍عز وجل។

ទ័ពបានបោះជំរំនៅទីនេះអស់រយៈពេលម្ភៃថ្ងៃ។ បន្ទាប់ពីបានយល់ជាក់ថាគោលដៅទាំងអស់បានសម្រេចសព្វគ្រប់ហើយ ព្រះសាស្តាﷺបានបញ្ជាឲ្យដកថយទៅកាន់ម៉ាឌីណាស់វិញ។

## ផែនការសម្ងាត់របស់ពួកលាក់ពុតត្បុត

តាមផ្លូវត្រឡប់មកវិញ ពួកពុតត្បុតដែលលាក់ខ្លួនក្នុងចំណោមពួកមុស្លីមបានឆ្លៀតយកឱកាសពេលយប់លួចធ្វើឲ្យមេអូដ្ឋព្រះសាស្តាﷺដួលទៅក្នុងជ្រោះ។ តែផែនការអាក្រក់របស់បនក្បត់នេះត្រូវបរាជ័យ ព្រះសាស្តាﷺបានរួចព្រះជន្ម។

បណ្តាអ្នកមានសទ្ធាជ្រះថ្លាមួយចំនួនក្រេវយ៉ាងខ្លាំង ប៉ងសម្លាប់ជនឧក្រិដ្ឋ តែព្រះសាស្តាបានធ្វើអន្តរាគមន៍ អាស្រ័យព្រះហឫទ័យអធ្យាស្រ័យដែលព្រះអង្គﷺតែងតែមានជាទម្លាប់នោះ ព្រះអង្គﷺបានហាមឃាត់ពួកគេ។

លុះព្រះសាស្តាﷺបានមកដល់ម៉ាឌីណាស់ភ្លាម ព្រះអង្គﷺបានបញ្ជាឲ្យបំផ្លាញម៉ាស់យ៊ិដ្ឋរបស់ពួកពុតត្បុតចោលភ្លាម។ គោលបំណងពិតប្រាកដរបស់ពួកនេះត្រូវព្រះគម្ពីរគួរអានបកអាក្រាតឲ្យដឹងអស់។

ពួកពុតត្បុតមួយចំនួនបានភ្ញាក់រលឹកដឹងកំហុស។ ព្រះសាស្តាﷺក៏បានលើកលែងទោសឲ្យពួកនេះ។

## ការបដិសេធពួកពហុទេពនិយម

ថ្ងៃទី១០ ខែស៊ុលហ៊ិច្ចយ៉ាស់ ឆ្នាំទី១០ សករាជហ៊ិច្ចរ៉ោះត៍ កាលដែលពួកពហុទេពនិយមអាចធ្វើពិធីធម្មយាត្រាបាននៅឡើយ អល់ឡោះហ៍عز وجلបានដាក់ចុះមកនូវស៊ូរ៉ោះត៍បដិសេធមកឲ្យព្រះសាស្តាﷺព្រះអង្គعز وجل (ឬស៊ូរ៉ោះត៍ភ្ញាក់រលឹកដឹងកំហុស ស៊ូរ៉ោះត៍ទី៩) ដែលប្រកាសសង្គ្រាមចំពោះពួកពហុទេពនិយមនិងពួកគោរពបូជារូបបដិមា។

ព្រះសាស្តាﷺបានឲ្យអាលីصلوات الله عليه والسلامសូត្រស៊ូរ៉ោះតូ៎នេះឲ្យអ្នកធ្វើពិធីធម្មយាត្រាទាំងអស់ ក្នុងឆ្នាំនោះ ស្តាប់ ហើយបានធ្វើសេចក្តីប្រកាសថា ចាប់ពីថ្ងៃនេះតទៅ អ្នកណាក៏ដោយដែលគោរពបូជារូបបដិមាត្រូវហាមចូលមកក្នុងព្រះមហាគ្រឹះស្ថានពិសិដ្ឋ។ ព្រះអង្គصلوات الله عليه والسلامបានប្រកាស ជាសង្ខេបថា៖ "ប្រជារាស្ត្រអើយ! ចាប់ពីពេលនេះតទៅ មិនអនុញ្ញាតឲ្យបុគ្គលគោរពបូជារូបបដិមាធ្វើពិធីធម្មយាត្រា(ពិធីហាច្ជ៏)ទេ។ មិនអនុញ្ញាតឲ្យបុគ្គលអាក្រាតដើរឆ្វេល(តូ៎វ៉ាហ្វ)កាក់បាស់ទេ។ បុគ្គលណាដែលបានធ្វើកិច្ចសន្យាជាមួយព្រះសាស្តាﷺ កិច្ចសន្យានោះមានសុពលភាពរហូតដល់កាលកំណត់។"

## ការដាក់បណ្តាសា(مباهلة)

ក្នុងចំណោមមហាក្សត្រដែលព្រះសាស្តាﷺបានផ្ញើលិខិតទៅ សូមឲ្យព្រមចូលជ្រកក្រោមសាសនាអ៊ីស្លាមនោះមានសង្ឃរាជមួយអង្គនៃតំបន់ណាច្ជ៉រ៉ន់(តំបន់ព្រំប្រទល់ខាងជើងនៃប្រទេសយេមេន)។

សង្ឃរាជរូបនេះបានរង់ចាំស្រាប់ហើយថា នឹងមានសាស្តាមួយអង្គនឹងមកស្តារជាថ្មីសាសនារបស់យេស៊ូ ព្រោះមានប្រផ្នូលជាមុនស្រេចហើយនៅក្នុងព្រះគម្ពីរអ៊ិនយ៉ីលនោះ។ ដើម្បីស៊ើបអង្កេតរកការខុសត្រូវក្នុងរឿងសាស្តាភាពរបស់មូហាំម៉ាដ់ﷺ សង្ឃរាជរូបនេះបានចាត់បញ្ជូនប្រតិភូមកកាន់ម៉ាឌីណាសុំឲ្យបំពេញបេសកកម្មនេះ។ ការសន្ទនារបស់បណ្តាសង្ឃរាជជាមួយព្រះសាស្តាﷺផ្តល់នូវលទ្ធផលយ៉ាងច្រើន។ លុះបានដល់សំណួរដែលសួរថាតើយេស៊ូ(អ៊ីសា)ជាកូនរបស់ព្រះមែនឬទេនោះ ហើយព្រះសាស្តាﷺឆ្លើយតបវិញតាមព្រះគម្ពីរគូរអាននោះថា៖ "*[ស៊ិ.៥, អា.៧៥] អាល់-ម៉ាសុិះហ៍ បុត្ររបស់ម៉ារយ៉ាំ គ្រាន់តែជាព្រះសាស្តាទេ ។ មានព្រះសាស្តាច្រើនទៀតបានកន្លងផុតមុនគេទៅហើយ ។ មាតារបស់គេជាសច្ចការិនី ។ អ្នកទាំងពីរបរិភោគអាហារ ។ [ស៊ិ.៣, អា.៥៩] ការពិត សម្រាប់អល់ឡោះហ៍ អ៊ីសាប្រៀបបាននឹងអាដាំ ។ ព្រះអង្គបានបង្កើតគេមកពីដីឥដ្ឋ បន្ទាប់មកព្រះអង្គមានព្រះតម្រាស់ចំពោះគេថា៖ "ចូរកើតឡើង!" គេក៏កើតឡើង ។*"

ប្រតិភូណាច្ជ៉រ៉នដែលមានគ្នាហុកសិបនាក់ លុះបានចូលដល់ចំណុចពិបាកនេះ មិនព្រមជឿថាមូហាំម៉ាដ់ﷺជាព្រះសាស្តាﷺទេ។ ព្រះសាស្តាﷺមូហាំម៉ាដ់ﷺបានបបួលពួកគេប្រកួត។ ព្រះអង្គﷺបានស្នើឲ្យពួកគេពោលពាក្យដាក់បណ្តាសាគ្នាទៅវិញទៅមកដើម្បីសូមឲ្យព្រះឆាប់កាត់ក្តីអ្នកណាដែលមិនជឿសេចក្តីពិតនោះ។

*[ស៊ិ.៣, អា.៦១] ដូច្នេះអ្នកណាមួយឈ្លោះប្រកែកជាមួយអ្នកក្នុងរឿងនេះ បន្ទាប់ពីព្រះអភិញ្ញាបានមកដល់អ្នកហើយនោះ ចូរអ្នកថា៖ "អស់លោកចូរមកចុះ យើងនឹងហៅកូនប្រុសៗយើងនិងកូនប្រុសៗរបស់អស់លោក បណ្តាស្ត្រីរបស់យើងនិងបណ្តាស្ត្រីរបស់អស់លោក ខ្លួនយើងផ្ទាល់និងខ្លួនអស់លោកផ្ទាល់ រួចហើយយើងបួងសួង សូមឲ្យព្រះបណ្តាសារបស់អល់ឡោះហ៍ពើបពះលើមុសាវាទី(អ្នកនិយាយកុហក) ។*"

លុះបានមកកាន់កន្លែងណាត់ជួបគ្នាធ្វើការដាក់បណ្តាសាគ្នាទៅវិញទៅមកនោះ បណ្តាសង្ឃរាជខ្លាចត្រូវបណ្តាសាអល់ឡោះហ៍عزّ وجلّពេលពួកគេបានឃើញបុគ្គលដណ្តប់ផួយទាំងប្រាំរូប(អាស់ហុល-គីសាអ៍) ដែលពុំមែនអ្នកណាក្រៅពីព្រះសាស្តាﷺ ហ្វាទីម៉ាស់سلام الله عليها ព្រះរាជបុត្រីរបស់ព្រះអង្គﷺ អាលីصلوات الله عليه والسلام ព្រះស្វាមីរបស់ព្រះនាងسلام الله عليها និងព្រះរាជបុត្រទាំងពីររបស់ព្រះអង្គعليهم السلام អាល់-ហាសាន់صلوات الله عليه والسلامនិងអាល់-ហ៊ូសៃន៍صلوات الله عليه والسلام នោះទេ។

សង្ឃរាជមួយអង្គបានបែរទៅប្រាប់កនខ្លួនថា៖ "សូមស្បថលើអល់ឡោះហ្ស៍! អ្នកណាប្រឈមតទល់នឹងបុគ្គលទាំងនេះ អ្នកនោះសមនឹងត្រូវបណ្តាសារបស់អល់ឡោះហ្ស៍عز وجل។

អ្វីដែលគួរឲ្យចាប់អារម្មណ៍បំផុតនៅក្នុងទំព័រប្រវត្តិសាស្ត្រអ៊ីស្លាមថ្មីមួយនេះ គឺការប្រើអាយ៉ាត់គួរអានដែលត្រូវបានដាក់ចុះមកឲ្យព្រះសាស្តាﷺក្នុងរឿងនេះ ស្តីអំពីបុគ្គលហ៊ុមជួយទាំងប្រាំអង្គ។ ពិតណាស់ នៅក្នុងព្រះគម្ពីរគួរអានគេឃើញមានចារថា៖ "ហៅកូនប្រុសៗយើងនិងកូនប្រុសៗរបស់អស់លោក"។ ច្បាស់ណាស់ ត្រង់នេះព្រះសាស្តាﷺបាននាំមកជាមួយព្រះអង្គﷺតែអាល់-ហាសាន់صلوات الله عليه والسلامនិងអាល់-ហ៊ូសៃន៍صلوات الله عليه والسلامទេ។ បន្ទាប់មក គួរអានចែងថា៖ "បណ្តាស្ត្រីរបស់យើងនិងបណ្តាស្ត្រីរបស់អស់លោក" គេឃើញថាស្ត្រីម្នាក់គត់ដែលមាននៅត្រង់នេះគឺព្រះសន្តនារីហ្វាទីម៉ាស់سلام الله عليها។ ពេលព្រះមហេសីមួយអង្គរបស់ព្រះសាស្តាﷺចង់មកកាន់ទីនេះដែរ ព្រះសាស្តាﷺបានឃាត់យ៉ាងម៉ឺងម៉ាត់។

បន្ទាប់មកគួរអានចែងថា៖ "ខ្លួនយើងផ្ទាល់និងខ្លួនអស់លោកផ្ទាល់"។ ត្រង់នេះហើយដែលការបកស្រាយសក្តិសមតែមួយគត់នោះបានតម្រូវឲ្យយើងសម្រេចថា៖ អ៊ាលីصلوات الله عليه والسلامជិតស្និទ្ធជាមួយព្រះសាស្តាﷺណាស់ ដល់ថ្នាក់អល់ឡោះហ្ស៍عز وجلបានធ្វើឲ្យខ្លួនអ៊ាលីصلوات الله عليه والسلامដូចខ្លួនព្រះអង្គﷺដែរ... ឯកសិទ្ធិរបស់សាច់ញាតិបរិសុទ្ធរបស់ព្រះសាស្តាﷺទាំងនេះនឹងនាំមកនូវសេចក្តីច្រណែន កំហឹងនិងគំនុំពីបណ្តាជនអប្រិយនៃឧបទ្វីបអារ៉ាប់។

ដោយដឹងថាមុស្លីមភាគច្រើនទើបនឹងបានពាល់ថើៗជំនឿដ៏ជ្រៅរបស់សាសនាអ៊ីស្លាម កាលពួកគេបានរងមរណៈទុក្ខរបស់ព្រះសាស្តាﷺនិងការតែងតាំងអ្នកស្នងព្រះអង្គﷺនោះ គេអាចអានបានយ៉ាងងាយស្រួលនូវទំព័រមួយដែលស្តីអំពីដំណាក់កាលមួយដែលប្រកបដោយការជំទាស់ក្នុងប្រវត្តិសាស្ត្រអ៊ីស្លាម។

## **ធម្មយាត្រាលាគ្នា**(حجة الوداع)

បណ្តាមុស្លីមមានសេចក្តីរីករាយណាស់ដែលព្រះសាស្តាﷺបានប្រកាសថា ព្រះអង្គﷺមានព្រះបំណងយាងទៅបំពេញពិធីធម្មយាត្រា ដោយអញ្ជើញនរូជនណាដែលមានសមត្ថភាពចូលរួមបាន។ ថ្ងៃទី២៥ ខែស៊ុលក៏អ៊ីដ្ហាស់ ឆ្នាំទី១០ សករាជហ៊ីជ្ជរ៉ោះត៍ ព្រះសាស្តាﷺបានចាកចេញពីនគរម៉ាឌីណាស់ទៅកាននគរម៉ាក់កាស់ជាមួយបក្សពួករួមពិធីធម្មយាត្រាយ៉ាងច្រើន នេះគឺធម្មយាត្រាធំ(ហាច្ជ៍)។

លុះបានទៅដល់ស៊ុលហ៊ូឡៃហ្វាស់(ذوالحليفة) ព្រះសាស្តាﷺបានចាប់ផ្តើមពិធីដោយគ្រងសំលៀកបំពាក់អិះហ៊្រ៉ម(إحرام) បន្ទាប់មកព្រះអង្គﷺបានសូត្រតាល់បីយ៉ាស់។

បន្ទាប់ពីបានដើរអស់ដប់ថ្ងៃ មុស្លីមបូជនីយេសក៍បានមកដល់ព្រះមហាគ្រឹះពិសិដ្ឋ ក្រោមការដឹកនាំរបស់ព្រះសាស្តាﷺ។ ពួកគេបានដើរឆ្វេលកាក់ុបាស់ប្រាំពីរជុំ បានធ្វើការដើរទៅមករវាងស្វ៊ហ្វានិងម៉ារវ៉ាស់។ ពេលព្រះសាស្តាﷺបានឡើងទៅលើភ្នំស្វ៊ហ្វា ព្រះអង្គﷺបានសូត្រថា៖ "ពុំមានព្រះផ្សេងពីអល់ឡោះហ្ស៍عز وجلទេ ព្រះមួយគត់ ព្រះអង្គعز وجلមិនមានដៃគូទេ។ អំណាចគ្រប់គ្រងនិងសេចក្តីសើចសរសើរជាកម្មសិទ្ធិរបស់ព្រះអង្គعز وجل។ ព្រះអង្គعز وجلមានសព្វានុភាពលើអ្វីៗទាំងអស់។ ពុំមានព្រះផ្សេងពីអល់ឡោះហ្ស៍عز وجلទេ ព្រះអង្គعز وجلបានគាំទ្របុគ្គលអ្នកគោរពបូជាព្រះអង្គعز وجل ហើយព្រះអង្គعز وجلបានបង្ក្រាបបណ្តាបក្សសម្ព័ន្ធដោយព្រះអង្គឯង។

នេះគឺពិធីធម្មយាត្រា(ហាច្ជ៍)ដែលគ្រប់បរិបូរបំផុតក្នុងប្រវត្តិសាស្ត្រអ៊ីស្លាម ហើយជាពិធីធម្មយាត្រាក្រោយបង្អស់របស់ព្រះសាស្តាﷺ។ ដោយដឹងថាជាគ្រាចុងក្រោយបង្អស់របស់ព្រះអង្គﷺ ព្រះសាស្តាﷺបានខិតខំប្រឹងប្រែងអធិប្បាយពន្យល់មុស្លីមទាំងអស់ នូវអ្វីដែលពួកគេមិនទាន់បានដឹងទាក់ទងនឹងសាសនារបស់ពួកគេ។

ពិធីធម្មយាត្រាបានចប់ហើយ ព្រះសាស្តាﷺបានប្រឈមនឹងបញ្ហាធំបំផុត ក្នុងការផ្សព្វផ្សាយព្រះរាជសារ គឺ៖ តើមុស្លីមទាំងនេះ ដែលជឿដោយពេញចិត្តនិងមិនពេញចិត្តនោះ នឹងព្រមទទួលអ្នក ស្នងព្រះអង្គﷺឬទេ គឺអាណាព្យាបាលដែលអល់ឡោះហ៊្ញﷻបានជ្រើសរើសនោះ?

វ៉ាហ៊ី(ការបើកឲ្យដឹង)អល់ឡោះហ៊្ញﷻបានទាញព្រះសាស្តាﷺពីការជញ្ជឹងគិតនេះ។ អល់ឡោះហ៊្ញﷻបានដាក់ព្រះបញ្ជាឲ្យប្រកាសវគ្គចុងក្រោយនៃការផ្សព្វផ្សាយព្រះរាជសារ ឲ្យបូជនីយេសក៏រាប់ពាន់នាក់នោះជ្រាបដឹង។ ដោយដឹងថាដំណឹងនេះនឹងធ្វើមនុស្សមួយចំនួនពិបាកនឹងទទួលយកបាន ព្រះសាស្តាﷺបានជ្រើសរើសយកឱកាស កន្លែងនិងសម្តីសមរម្យបំផុតសម្រាប់អនុវត្តិតាមព្រះបញ្ជាអល់ឡោះហ៊្ញﷻគឺ៖ [៥:៦៧] *សាស្តាអើយ ចូរអ្នកផ្សព្វផ្សាយអ្វីដែលគេបានប្រទានចុះមកឲ្យអ្នកពីព្រះម្ចាស់អ្នកទៅ បើអ្នកមិនធ្វើទេ អ្នកពុំបានផ្សព្វផ្សាយនូវព្រះរាជសាររបស់ព្រះអង្គទេ...*

## នៅឯបឹងឃុម

ព្រះសាស្តាﷺបានប្រជុំបូជនីយេសក៏ទាំងអស់ ដែលមានចំនួនលើសពី ១០០ ០០០ នាក់ នៅជុំវិញបឹងនៃស្រុកឃុម ថ្ងៃទី១៨ ខែស៊ុលហ៊ិច្ជយ៉ាស់ ក្រោយពីបានចប់ពិធីធម្មយាត្រាសព្វគ្រប់ហើយ ពេលត្រឡប់ទៅកាន់នគរម៉ាឌីណាស់វិញ។

ការជួបជុំគ្នានេះបានប្រព្រឹត្តទៅនៅក្រោមថ្ងៃក្តៅហែង។ ដើម្បីនឹងឲ្យមនុស្សទាំងអស់ដែលមានវត្តមាននៅទីនោះបានឃើញព្រះអង្គﷺ ព្រះសាស្តាﷺបានឲ្យគេសង់វេទិកាមួយ។ ព្រះអង្គﷺបានឡើងទៅលើនោះដោយមានអ៊ាលីصلوات الله عليه والسلام សាវកភក្តីរបស់ព្រះអង្គﷺតាមក្រោយផង។ បន្ទាប់មក ព្រះអង្គﷺបានប្រកាសចំពោះប្រជុំជនដែលអន្ទះសាចាំស្តាប់សុន្ទរកថារបស់ព្រះបរមគ្រូរបស់ខ្លួននោះថា៖ "*សូមថ្វាយសេចក្តីសរសើរចំពោះអល់ឡោះហ៊្ញ។ អស់ទូលព្រះបង្គំជាខ្ញុំសូមថ្វាយសេចក្តីសរសើរចំពោះព្រះអង្គﷻ, អស់ទូលព្រះបង្គំជាខ្ញុំសូមជំនួយពីព្រះអង្គصلوات الله عليه والسلام អស់ទូលព្រះបង្គំជាខ្ញុំសូមខមាទោសចំពោះព្រះអង្គﷻ,...*"

ព្រះសាស្តាﷺបានធ្វើសុន្ទរកថាដ៏វែងមួយ។ នៅក្នុងសុន្ទរកថានោះព្រះអង្គﷺបានអធិប្បាយពន្យល់នូវជនទាំងឡាយដែលមានវត្តមាននៅទីនោះអំពីគោលនៃច្បាប់អ៊ីស្លាមទាំងឡាយ។ ចប់ហើយព្រះអង្គﷺបានចាប់ដៃអ៊ាលីصلوات الله عليه والسلامលើកឡើងលើដើម្បីឲ្យទាំងអស់គ្នាបានឃើញ ហើយព្រះអង្គﷺមានព្រះវចនៈថា៖ "*អ្នកណាក៏ដោយដែលមានខ្ញុំﷺព្រះបរមគ្រូ អ៊ាលីصلوات الله عليه والسلامជាព្រះបរមគ្រូរបស់អ្នកនោះ។ អល់ឡោះហ៊្ញﷻ,អើយ! សូមព្រះអង្គឪញជាមិត្តរបស់បុគ្គលណាដែលជាមិត្តរបស់គេصلوات الله عليه والسلام សូមព្រះអង្គﷻ,ជាសត្រូវរបស់បុគ្គលណាដែលជាសត្រូវ*

*របស់គេ* صلوات الله عليه والسلام *។"*

បន្ទាប់មកព្រះសាស្ដាﷺមានព្រះវចនៈថា៖ "ខ្ញុំﷺបានទុកឲ្យអស់លោកនូវទម្ងន់បន្ទុកពីរគឺ៖ ព្រះគម្ពីររបស់អល់ឡោះហ្ម៍عزّ وجلّ និងបណ្ដាកូនចៅអាស្ហលុល-បៃត៍របស់ខ្ញុំﷺ។ ដរាបណាអស់លោកតោងជាប់ទាំងពីរនេះ ដរាបនោះអស់លោកនឹងមិនវង្វេងជាដាច់ខាត។ ដូច្នេះ ចូរអស់លោកប្រុងប្រយ័តថានឹងត្រូវប្រព្រឹត្តបែបណាខ្លះជាមួយទាំងពីរនេះ អត់ពីខ្ញុំﷺទៅ !"

ចប់សុន្ទរកថានេះភ្លាម ដែលហៅថាសុន្ទរកថាក៏ុខ្មៀរ(បឹង)នោះ អល់ឡោះហ្ម៍عزّ وجلّបានដាក់ចុះមកនូវស្ហ៊ូរ៉ោះត៍ចុងក្រោយបង្អស់របស់ព្រះគម្ពីរគួរអាន គឺ៖ "[៥:៣]...*ថ្ងៃនេះអញបានធ្វើឲ្យសាសនារបស់ពួកអ្នកសុក្រឹតឥតខ្ចោះ បានបង្គ្រប់ឧបការធម៌អញលើពួកអ្នក ហើយអញបានជ្រើសយកអ៊ីស្លាមជាសាសនាសម្រាប់ពួកអ្នក*..."



## ព្រះទិវង្គត

បន្ទាប់ពីបានត្រឡប់មកដល់ម៉ាឌីណាស្ហ៍វិញ ព្រះសាស្តាﷺត្រូវជម្ងឺគ្រុនក្តៅបៀតបៀន បង្ខំឲ្យព្រះអង្គﷺគង់នៅក្នុងព្រះរាជដំណាក់អស់ពីរបីថ្ងៃ។

ក្នុងចន្លោះពេលនេះ ដោយបានឃើញព័ត៌មានសាសនាអ៊ីស្លាមនិងសាសនាអ៊ីស្លាមរីកសុសសាយទៅដល់គ្រប់កុលសម្ព័ន្ធអារ៉ាប់ ជនបោកប្រាស់នៃឧបទ្វីបអារ៉ាប់បានគិតថានេះគឺឱកាសល្អមួយដើម្បីប្រកាសថាខ្លួនជាសាស្តានិងទាក់ទាញជនខ្សោយប្រាជ្ញាដែលនៅជុំវិញខ្លួន។

ដូច្នេះទូឡៃហាស្ហ៍ អាល់-អាស៊ីឌី(طليحة الأسدي), អាស់វ៉ាដ់ អាល់-អ៊ាន់ស៊ី(الاسود العنسي), មូសៃឡាម៉ាស្ហ៍(مسيلمة) ជនបោកប្រាស់និងជនអប្រិយមួយចំនួនទៀតបានអះអាងថាខ្លួនជាអ្នកនាំព្រះរាជសារ។ អាស្រ័យហេតុនេះពួកគេប្រមូលបាននូវមនុស្សអវិជ្ជានិងខ្សោយប្រាជ្ញាមួយក្រុម... តែការបង្កចលាចលរបស់ពួកគេនេះមិនឋិតថេរទេ។ អល់ឡោះហ៊្ជបានពន្លត់ភ្លើងពួកគេ ឧបទ្វីបអារ៉ាប់ក៏បានវិលត្រឡប់ទៅនៅក្រោមអាជ្ញាអ៊ីស្លាមវិញយ៉ាងឆាប់រហ័ស។

យប់មួយ ព្រះសាស្តាឱ្យចផ្ទំមិនលក់ក៏បានហៅអ៊ុលីصلوات الله عليه والسلام មកប្រាប់ថា៖ *"គេទើបនឹងបានបញ្ជាឲ្យខ្ញុំﷺ អង្វរបួងសួងសូមខមាទោសឲ្យអ្នកបាគ្គីអ៊ មកជាមួយខ្ញុំﷺ!"*

មកដល់បាគ្គីអ៊ ព្រះសាស្តាﷺមានព្រះវចនៈថា៖ *"គេបានស្នើសូមប្រគល់ហិបនៃលោកនេះនិងអនន្តភាពឲ្យមកខ្ញុំﷺ ។ ខ្ញុំﷺមានជម្រើសជ្រើសយកអ្វីទាំងនេះ ឬជ្រើសយកការជួបព្រះម្ចាស់ﷻ,ខ្ញុំﷺ ។ ខ្ញុំﷺជ្រើសយកការជួបព្រះម្ចាស់ﷻ,ខ្ញុំﷺនិងឋានសួគ៌ ។"*

អាការជម្ងឺព្រះសាស្តាﷺ បានដុនដាបជារៀងរាល់ថ្ងៃ... ថ្ងៃទី ២៨ ខែស្ហ៍ហ្វារ ឆ្នាំទី ១១ សករាជហ៊ីចរ៉ោះត៍ ព្រះវិញ្ញាណព្រះសាស្តាﷺបានឆ្ពោះឡើងទៅរកព្រះម្ចាស់ﷻព្រះអង្គﷺ ទុកឲ្យរាប់ពាន់ភ្នែកយំយែកយ៉ាងសស្រាក់សស្រាំ ទ្រូងប្រេះឆា។ សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គﷺ ថ្ងៃព្រះអង្គﷺទ្រង់ប្រសូត ថ្ងៃព្រះអង្គﷺទ្រង់សោយព្រះទិវង្គត និងថ្ងៃព្រះអង្គﷺទ្រង់មានព្រះជន្មឡើងវិញ។

## អត្តសញ្ញាណប័ណ្ណ

-ព្រះនាម ៖ មូហាំម៉ាដ់

-នាមបិតា ៖ អ៊ាប់ឌុលឡោះហ៊្

-នាមមាតា ៖ អាមីណាស្ហ៍

-ស្រុកកំណើត ៖ ម៉ាក់កាស្ហ៍

-ថ្ងៃកំណើត៖ ១៧ រ៉ប់ប៊ីអ៊ុ អាល់-អាវ៉ាល់ ឆ្នាំដំរី (គ្រិស្តសករាជ ៥៧០)

-ថ្ងៃចូលទិវង្គត ៖ ២៨ ស្វ៍ហ្វារ ឆ្នាំ ១១ សករាជហ៊ីជ្រ៉ោះគ៍

-កន្លែងចូលទិវង្គត ៖ ម៉ាឌីណាស់

## សម្រង់ព្រះវចនៈត្រចះត្រចង់

-គោរពពាក្យសន្យាជាជំនឿមួយ។

-អ្នកណាមានចរិយាធម៌ប្រសើបំផុត អ្នកនោះមានជំនឿប្រសើរបំផុត។

-ចរិយាល្អពង្រឹងមិត្តភាព។

-ខ្សែភ្នែកប្រកបដោយសេចក្ដីស្រឡាញ់របស់កូនចំពោះឪពុកម្ដាយ ជាសេចក្ដីគោរពអល់ឡោះហ្ ﷻយ៉ាងជ្រាលជ្រៅ។

-សេចក្ដីរមទមជាជំនឿមួយ។